# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣៧*៧៩

# ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ
# នៅក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
# ២០១១-២០១៥




រៀបចំដោយ

ក្រុមការងារយេនឌ័រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សហការជាមួយគម្រោង ***ភាពជាដៃគូដើម្បីសមធម៌យេនឌ័រ*** នៃក្រសួងកិច្ចការនារី

និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ( UNDP )

# មាតិកា


**បុព្វកថា** ---------------------------------------------------------------- ៣

**សេចក្តីថ្លែងអំណរគុណ** -------------------------------------------------------- ៤

**ជំពូកទី ១ ស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជា** ------------------------------------- ៥

**ជំពូកទី ២ ស្ថានភាពទូទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ---------------- ៩

២.១ ប្រវត្តិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ----------------------------- ៩

២.២ មុខងារ និងភារកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ------------------- ៩

២.៣ ប្រវត្តិក្រុមការងារយេនឌ័រ ---------------------------------------------- ១០

**ជំពូកទី ៣ ការវិភាគយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ------------ ១២

៣.១ ក្របខ័ណ្ឌច្បាប់គតិយុត្ត និងគោលនយោបាយផ្សេងៗឆ្លើយតបនឹងយេនឌ័រ ---------------------- ១២

៣.២ ការវិភាគយេនឌ័រនៅក្នុងកម្រិតស្ថាប័ន ----------------------------------------- ១៣

៣.២.១ តួនាទីធ្វើសេចក្តីសម្រេចរបស់ស្ត្រីនៅក្នុងក្រសួង ------------------------------- ១៣

៣.២.២ ការអភិវឌ្ឍធនធានមនុស្ស ------------------------------------------- ១៥

៣.៣ ការវិភាគយេនឌ័រនៅក្នុងកម្រិតអ្នកទទួលផលពីសេវាសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ------------- ១៦

៣.៣.១ សេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រងាយរងគ្រោះ ------------------------- ១៦

៣.៣.២ សេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា ------------------------------ ១៧

៣.៣.៣ សេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម -------------------------- ១៧

៣.៣.៤ របបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ --------------- ១៨

៣.៣.៥ របបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន ---------------------------- ១៩

**ជំពូកទី ៤ ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១១-២០១៥** ------------------------------ ២០

**ឧបសម្ព័ន្ធ** ---------------------------------------------------------- ២៨

- **គោលការណ៍ណែនាំសម្រាប់ក្រុមការងារយេនឌ័រនៅតាមក្រសួងពាក់ព័ន្ធនានា**
- **សមាជិកភាពក្រុមការងារយេនឌ័រនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
- **ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០១១- ២០១៥**
- **បញ្ជីត្រួតពិនិត្យសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី ឬ គម្រោង**
- **វាក្យស័ព្ទបច្ចេកទេសយេនឌ័រ**

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងការកាត់បន្ថយភាពក្រីក្រជូនប្រជាជន ដូចបានកំណត់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ហើយក្នុងនោះបញ្ហាយេនឌ័រ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ ដោយចាត់ទុក " ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ " នៅក្នុងដំណើរការអភិវឌ្ឍប្រទេសជាតិ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យធំៗបីគឺ វិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា ដើម្បីបង្កើនអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច ជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះក្នុងសង្គម និងបង្កើតនូវប្រព័ន្ធសុវត្ថិភាពសង្គមរបស់អតីតមន្ត្រីរាជការ អតីតយុទ្ធជន និងប្រជាពលរដ្ឋទូទៅ ។

ដើម្បីបញ្ជាក់នូវការប្តេជ្ញាចិត្ត ក្នុងការលើកកម្ពស់ស្ថានភាពយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៅក្នុងផែនការសកម្មភាពរបស់ខ្លួនសម្រាប់ចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា និងក្នុងឯកសារបឋម ស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃគោលនយោបាយសុវត្ថិភាពសង្គមរបស់រាជរដ្ឋាភិបាល សំដៅកាត់បន្ថយគម្លាតយេនឌ័រក្នុងវិស័យនេះលើកកម្ពស់សិទ្ធិស្ត្រី ពង្រឹងភាពអង់អាចដល់ស្ត្រី កែប្រែជីវភាពស្ត្រីក្រីក្រនៅជនបទ និងបង្កើនចំនួនតំណាងស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច ។

ដូចនេះដើម្បីអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដូចដែលបានលើកឡើងក្នុងឯកសារគោលទាំងពីរខាងលើ ក្រសួងដាក់ចេញនូវផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ឆ្នាំ ២០១១ - ២០១៥ សម្រាប់ការតាមដាន ត្រួតពិនិត្យការអនុវត្តទាំងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងស្ថាប័នផ្ទៃក្នុងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទាំងក្នុងវិស័យការងារជំនាញដែលស្ថិតក្នុងអាណត្តិបេសកកម្មរបស់ក្រសួង ។

តាមរយៈឯកសារនេះ ខ្ញុំសូមអំពាវនាវសុំឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធ និងគាំទ្រយ៉ាងសកម្ម ទាំងស្មារតីបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមការងារយេនឌ័ររបស់ក្រសួងពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការមិនមែនរដ្ឋាភិបាលនានា និងដៃគូអភិវឌ្ឍន៍ ដើម្បីឱ្យផែនការយុទ្ធសាស្ត្រ ដែលក្រសួងបានដាក់ចេញនេះសម្រេចបានដោយជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងារយេនឌ័ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសេចក្តីសោមនស្សរីករាយឥតឧបមា និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលជានិច្ចកាលតែងតែយកចិត្តទុកដាក់ផ្តួចផ្តើមគំនិត និងផ្តល់ការគាំទ្រព្រមទាំងលើកទឹកចិត្តដល់ក្រុមការងារយេនឌ័រ របស់ក្រសួងក្នុងដំណើរការ រៀបចំផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានេះ ។

ជាមួយគ្នានេះដែរ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះកិច្ចសហការគាំទ្រ និងការចូលរួមយ៉ាងសកម្មរបស់គម្រោងភាពជាដៃគូដើម្បីសមធម៌យេនឌ័រ ជាពិសេសលោកជំទាវ **សុខ ច័ន្ទឆវី** ទីប្រឹក្សាជាន់ខ្ពស់របស់កម្មវិធីអភិវឌ្ឍសហប្រជាជាតិ ( UNDP ) និងលោកស្រី **សូ រដ្ឋាវី** មន្ត្រីគម្រោងកម្មវិធីអភិវឌ្ឍសហប្រជាជាតិ ( UNDP ) ដែលបានគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាក្នុងការរៀបចំផែនការសកម្មភាពបញ្ជ្រាបយេនឌ័រចាប់ពីដំណាក់កាលដំបូងរហូតដល់បានបញ្ចប់ដោយជោគជ័យ ។

ជាចុងក្រោយនេះដែរ យើងក៏សូមថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចូលរួមផ្តល់យោបល់ ព័ត៌មាន ឯកសារ និងទន្នន័យផ្សេងៗ ដើម្បីឱ្យក្រុមការងារយេនឌ័រទទួលបានជោគជ័យក្នុងការរៀបចំបង្កើតឯកសារនេះ ។

**ប្រធានក្រុមការងារយេនឌ័រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

**ឈាង ឆាត់**

# ជំពូកទី ១ ស្ថានភាពយេនឌ័រនៅប្រទេសកម្ពុជា

ស្ថានភាពយេនឌ័រក្នុងប្រទេសកម្ពុជា មានការរីកចម្រើនកាន់តែប្រសើរឡើង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ របាយការណ៍ពិភពលោក ស្តីពីការអភិវឌ្ឍមនុស្សឆ្នាំ ២០០៨ បានបង្ហាញថាក្នុងចំណោម ១៥៧ ប្រទេស សន្ទស្សន៍អភិវឌ្ឍន៍យេនឌ័ររបស់កម្ពុជានៅក្នុងឆ្នាំ ២០០៦ ស្ថិតក្នុងលំដាប់ទី ៦៦ ដោយបានថយចុះពីលំដាប់ទី ៦៧។ ដោយឡែកវិធានការពង្រឹងភាពអង់អាចយេនឌ័រ ស្ថិតក្នុងលំដាប់ទី ៩៨ ក្នុងចំណោមប្រទេស ១០៨ ។ ទោះជាយ៉ាងនេះក្តីប្រទេសកម្ពុជានៅតែមានបញ្ហាប្រឈមមុខផ្សេងទៀតជាច្រើនដែលត្រូវដោះស្រាយ ។

ការលើកកម្ពស់អំពីតម្លៃស្ត្រី និងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គម គឺជាកិច្ចការមួយដ៏លំបាក ជាពិសេសសម្រាប់ប្រជាជនទាំងឡាយដែលរស់នៅក្នុងតំបន់ជនបទ ដែលប្រពៃណីបុរាណបានចាក់ឫសយ៉ាងជ្រៅក្នុងផ្នត់គំនិតរបស់ពួកគាត់។ ក្នុងសង្គមខ្មែរ បុរសត្រូវបានគេទទួលស្គាល់ថាជាអ្នកមានឥទ្ធិពល និងមានអំណាចជាងស្ត្រី ទោះបីជាស្ត្រីជាបុគ្គលយ៉ាងសំខាន់នៅក្នុងការបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ និងទទួលបន្ទុកយ៉ាងធំក៏ដោយ។ ដូចនេះ បុរសតែងតែជាអ្នកធ្វើការសម្រេចចិត្តទៅលើកិច្ចការសំខាន់ៗក្នុងគ្រួសារ ក៏ដូចជានៅក្នុងសង្គម ។

យោងតាមរបាយការណ៍ចំណែកស្មើគ្នា សម្រាប់នារីរបស់ក្រសួងកិច្ចការនារីខែមេសា ឆ្នាំ ២០០៨ សព្វថ្ងៃនេះស្ត្រីជាមេគ្រួសារមានចំនួន ២២ ភាគរយ ដែលភាគច្រើនក្នុងចំនួននេះ ត្រូវបានកំណត់ថាជាប្រជាជនដែលក្រីក្របំផុតនៅទីជនបទ ។ នេះបានបង្ហាញឱ្យឃើញអំពីសម្ពាធមួយយ៉ាងធ្ងន់មកលើស្ត្រី ក្នុងការទទួលរ៉ាប់រងជាអ្នករកប្រាក់ចំណូលសម្រាប់ចិញ្ចឹមគ្រួសារ ។

ស្ត្រីបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួចមកគប្បីបម្រើស្វាមី ធ្វើជាភរិយាដ៏ល្អ ធ្វើជាម្តាយល្អ ដោយគោរពនិងស្តាប់ឱវាទស្វាមី ដោយពុំអនុញ្ញាតឱ្យធ្វើការនៅក្រៅផ្ទះឡើយ មានន័យថាជីវិតរបស់ស្ត្រីពុំមានការទំនាក់ទំនងក្នុងសង្គមខាងក្រៅទេ។ នៅក្នុងក្រុមគ្រួសារវិញ នៅពេលស្ត្រីទទួលបានការអប់រំតិចតួច បុរសភាគច្រើនទទួលការក្តាប់អំណាច និងការធ្វើសេចក្តីសម្រេចចិត្ត ។

លទ្ធផលអង្កេតឆ្នាំ ២០០៤ បានបង្ហាញថា ស្ត្រីចំណាយពេលច្រើនជាងបុរស ប្រហែល៣ម៉ោង ជារៀងរាល់ថ្ងៃសម្រាប់ធ្វើការងារផ្ទះសម្បែង និងថែទាំក្រុមគ្រួសារ ។ តាមការពិតស្ត្រីបានរួមចំណែកយ៉ាងច្រើននៅក្នុងវិស័យសេដ្ឋកិច្ច ប្រសិនបើយើងគណនាជាសាច់ប្រាក់វិញ សម្រាប់ការងារផ្ទះសម្បែងនេះស្ត្រីរកចំណូលបាន ៩ ពាន់លានរៀលក្នុងមួយថ្ងៃលើសបុរសចំនួន ៩ដង។ ទោះជាយ៉ាងនេះក្តីការងារទាំងនេះ មិនត្រូវបានរាប់បញ្ចូលទៅចំណូលសម្រាប់វិស័យសេដ្ឋកិច្ចទេ ។

អត្រាគ្មានការងារធ្វើនៅក្នុងប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០០៤ គឺមានកម្រិតទាបបំផុតត្រឹមតែ០.៨ភាគរយប៉ុណ្ណោះ ប៉ុន្តែបើប្រៀបធៀបទៅនឹងឆ្នាំ ១៩៩៩ អត្រានេះបានកើនឡើងបន្តិច។ មូលហេតុគឺបណ្តាលមកពីមានការកើនឡើងដ៏គំហុកនៃចំនួនទារកដែលបានកើតនៅក្នុងអំឡុងឆ្នាំ ១៩៨០ ដែលជាហេតុធ្វើឱ្យទីផ្សារពលកម្មក្នុងប្រទេសកម្ពុជាមានលក្ខណៈពិសេសក្នុងអំឡុងឆ្នាំ ២០០០។ ចាប់ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០០៤ អត្រាចូលរួមកម្លាំងពលកម្មរបស់ស្ត្រីសរុបបានកើនឡើងចំនួន ៨.៥ ភាគរយ ពោលគឺស្មើនឹង ៧១ ភាគរយ ។

ចំនួនយុវជននៅក្នុងកម្លាំងពលកម្មដែលស្ថិតក្នុងក្រុមអាយុ ១៥ឆ្នាំ ដល់ ១៩ឆ្នាំ បានកើនឡើងចំនួន ១៩.៨ ភាគរយ ពោលគឺស្មើនឹង ៧២.៨ ភាគរយហើយសម្រាប់ក្រុមអាយុ ២០ឆ្នាំ ដល់ ២៤ ឆ្នាំវិញ បានកើនឡើងដល់ ៨៣.៦ ភាគរយ ។ នេះមានន័យថាជារៀងរាល់ឆ្នាំមានយុវជនប្រមាណជា ២៥០.០០០នាក់ បានចូលទៅក្នុងទីផ្សារពលកម្ម ។ ដូចនេះប្រទេសកម្ពុជាត្រូវប្រឈមមុខក្នុងការបង្កើតការងារឱ្យបានច្រើន ដើម្បីស្រូបយកកម្លាំងពលកម្មទាំងអស់នេះ ។

អត្រាចូលរួមរបស់ស្ត្រីក្នុងកម្លាំងពលកម្មបានកើនឡើងចំនួនពី ៤.៨ភាគរយ ដល់ ៨២ភាគរយនៅឆ្នាំ២០០១ និងធ្លាក់ចុះមកត្រឹម ៧១ ភាគរយនៅឆ្នាំ ២០០៤ ដែលជាផលធៀបទៅនឹងកំណើននៃអត្រានិស្សិតចុះឈ្មោះចូលរៀន ។ ទោះជាយ៉ាងនេះក្តី ក្នុងចំណោមកម្លាំងពលកម្មសកម្មសរុបនៃវិស័យសេដ្ឋកិច្ចស្ត្រី ៥២ ភាគរយ ធ្វើការងារគ្រួសារដែលគ្មានប្រាក់កម្រៃបើប្រៀបធៀបទៅនឹងបុរសចំនួន ៣៥ ភាគរយ ។

យោងតាមរបាយការណ៍របស់ក្រសួងកិច្ចការនារីឆ្នាំ ២០០៨ វិស័យឧស្សាហកម្មបានស្រូបយកកម្លាំងពលកម្មរហូតដល់ទៅ ១៣ ភាគរយនៃការងារសរុបនៅក្នុងឆ្នាំ ២០០៤ ទៅលើឧស្សាហកម្មកាត់ដេរ និងសំណង់ ។ ដោយឡែកឧស្សាហកម្មកាត់ដេរបានផ្តល់សារៈសំខាន់យ៉ាងខ្លាំងសម្រាប់សេដ្ឋកិច្ចកម្ពុជា ដោយទាក់ទាញកម្លាំងពេញវ័យបំពេញពលកម្មជាច្រើនទៅបម្រើការនៅក្នុងវិស័យនេះជាពិសេសស្ត្រីពេញវ័យបំពេញពលកម្មរហូតដល់ ៨០ ភាគរយ គឺស្មើនឹង ៣៤០.០០០ នាក់ ធ្វើការនៅក្នុងរោងចក្រប្រហែល ៤០០កន្លែង គេបានធ្វើការប៉ាន់ប្រមាណថា វិស័យនេះបានបង្កើតការងារដោយផ្ទាល់ដល់មនុស្សចំនួន ២៧០.០០០ នាក់ និងដោយប្រយោលចំនួន ២៤២.០០០ នាក់ ។ ដោយសម្ពាធសេដ្ឋកិច្ច ភាពក្រីក្រនិងការខ្វះឱកាសរកចំណូលនៅក្នុងតំបន់ជនបទត្រូវបានអូសទាញដោយឱកាសងាយរកបានចំណូលខ្ពស់ នៅទីក្រុងភ្នំពេញ តំបន់ទីប្រជុំជនផ្សេងៗទៀត និង នៅប្រទេសក្រៅជាហេតុធ្វើឱ្យមានការកើនឡើងនូវការធ្វើចំណាកស្រុក ដែលអ្នកទាំងនោះជាបុរស និងស្ត្រីវ័យក្មេង ដើម្បីស្វែងរកការងារធ្វើ ។ ដោយឡែកចំណាកស្រុកឆ្លងដែនក៏កំពុងកើនឡើង ជាពិសេសចំពោះបណ្តាខេត្តនៅតាមព្រំដែន។ តាមការប៉ាន់ប្រមាណមានកម្មករកម្មការិនីខ្មែរចំនួន ១៨០.០០០នាក់ ទៅធ្វើជាកម្មករពុំទៀងទាត់នៅក្នុងប្រទេសថៃ។ កម្មការិនីចំណាកស្រុកអាចរកបានពី ១០០-១៥០ ដុល្លាអាមេរិកក្នុងមួយខែ។ នៅក្នុងប្រទេសថៃ ដែលចំនួននេះមានទំហំច្រើនជាងចំណូល ដែលពួកគេអាចរកបាននៅក្នុងប្រទេស ។ ប៉ុន្តែពួកគេជួបប្រទះនូវបញ្ហាប្រឈមមុខជាច្រើនដូចជា ការរស់នៅខុសច្បាប់ ដែលធ្វើឱ្យមានការភ័យខ្លាចខ្វះសេរីភាព ពុំមានការងារធ្វើទៀងទាត់ អំពើហិង្សា លក្ខខណ្ឌការងារប្រកបដោយគ្រោះថ្នាក់ និងមានការលំបាកដោយខ្វះការថែទាំសុខភាព ចំណាយខ្ពស់លើការរស់នៅគ្មានប្រព័ន្ធសមរម្យនិងមានសុវត្ថិភាពសម្រាប់ការផ្ញើប្រាក់មកផ្ទះ ( យូនីហ្វេម ឆ្នាំ២០០៥ )។ ផ្អែកតាមរបាយការណ៍របស់វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា ឆ្នាំ ២០០៧ ប្រាក់ចំណូលរបស់កម្មករចំនួនពាក់កណ្តាលត្រូវបានចំណាយទៅលើម្ហូបអាហារ ថ្លៃឈ្នួលផ្ទះ និងការធ្វើដំណើរ ហើយពាក់កណ្តាលទៀតត្រូវបានទុកសម្រាប់ផ្គត់ផ្គង់គ្រួសារនៅឯជនបទ និងជាប្រាក់សន្សំ ។

កសិកម្មនៅតែជាវិស័យមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ដោយបានផ្តល់ការងារដល់ប្រជាជនរហូតដល់ ៦០ ភាគរយនៃប្រជាជនសរុប ហើយស្ត្រីចូលរួមចំណែកស្មើនឹង ៦២ ភាគរយ ដែលភាគច្រើននៃការងារនេះជាការប្រកបអាជីវកម្មដោយខ្លួនឯង ឬការងារគ្រួសារដែលគ្មានប្រាក់ចំណូល ។ ក្នុងរវាងបីឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់លើវិស័យកសិកម្មមានប្រាក់ឈ្នួល នេះដោយសារការកើនឡើងនៃភាពគ្មានដីធ្លី និងការងារ ផលិតកម្ម កសិកម្មទ្រង់ទ្រាយធំ ។ ស្ត្រីដែលជាមេគ្រួសារ និងស្ត្រីមេម៉ាយប្រឈមមុខធំបំផុតនៅក្នុងសិទ្ធិកាន់កាប់ដីធ្លីដែលគ្មានសុវត្ថិភាព ដោយសារពុំមានឯកសារពាក់ពន្ធ័ដីធ្លីច្បាស់លាស់ ព័ត៌មានជាក់លាក់នៅក្នុងដំណើរការចេញប័ណ្ណកម្មសិទ្ធិដីធ្លី ។ល ។

នៅក្នុងវិស័យអប់រំ អត្រាអនក្ខរភាពចំពោះស្ត្រីមានចំនួនខ្ពស់ជាងបុរសដោយសារស្ត្រីចំនួន ៤០ ភាគរយមិនចេះអាន និងមិនចេះសរសេរសោះធៀបនឹងបុរសដែលមានចំនួនតែ ២០ ភាគរយ ។ ប៉ុន្តែស្ត្រីចេះអាន និងសរសេរតិចតួចមានចំនួនច្រើនជាងបុរសពោលគឺមានស្ត្រីចំនួន ៧១ ភាគរយធៀបនឹងបុរស ៥០ ភាគរយ។ ចំពោះការបណ្តុះបណ្តាលទូទៅ គម្លាតរវាងសិស្សស្រី និងសិស្សប្រុសបានកើនឡើងខ្លាំងនៅពេលសិស្សទាំងនេះសិក្សានៅកម្រិតថ្នាក់ខ្ពស់។ ជាក់ស្តែងការសិក្សា នៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅឆ្នាំ ២០០៧ ចំនួនសិស្សស្រី និងសិស្សប្រុសស្ទើរតែប្រហាក់ប្រហែលគ្នា ពោលគឺសិស្សស្រីមានចំនួន ៩២ នាក់ ធៀបនឹងសិស្សប្រុស ១០០នាក់ នៅថ្នាក់បឋមភូមិស្មើនឹង ៩១ ភាគរយ នៃសិស្សស្រី ធៀបនឹង ៩៣ ភាគរយនៃសិស្សប្រុស។

ថ្នាក់មធ្យមសិក្សាបឋមភូមិសិស្សស្រីមានចំនួន ៣៣ ភាគរយ និងសិស្សប្រុសមានចំនួន ៣៤ ភាគរយ។ ក៏ប៉ុន្តែចំនួនសិស្សស្រីនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ មានចំនួនតិចជាងសិស្សប្រុស គឺសិស្សស្រីមានចំនួន ៦៦ នាក់ ធៀបនឹងសិស្សប្រុស ១០០ នាក់ ( ក្រសួងកិច្ចការនារី ២០០៨ ) ។ ការសិក្សានៅថ្នាក់ឧត្តមសិក្សាគម្លាតយេនឌ័ររបស់សិស្សទាំងពីរភេទ មានការថយចុះជាងឆ្នាំមុន ដោយថយពីសមាមាត្រសិស្សប្រុស ៣.៣ នាក់ ធៀបនឹងសិស្សស្រី ១ នាក់ មកសមាមាត្រ ២.១ ធៀបនឹង ១ នាក់ ។

អត្រាបោះបង់ចោលការសិក្សារបស់ក្មេងស្រីនៅតែមានកម្រិតខ្ពស់គួរឱ្យព្រួយបារម្ភ។ មូលហេតុដែលក្មេងស្រីបោះបង់ចោលការសិក្សាដោយសារផ្ទះនៅឆ្ងាយពីសាលារៀន គ្មានមធ្យោបាយធ្វើដំណើរ កង្វះខាតសម្ភារៈរូបវ័ន្តនៅសាលារៀន កង្វះខាតអន្តេវាសិកដ្ឋានសម្រាប់សិស្សស្រី គ្រួសារមានជីវភាពក្រីក្រ ការជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ ការជួយរំលែកការងារផ្ទះសម្បែង សុវត្ថិភាពក្មេងស្រី និងប្រពៃណីដែលរារាំងមិនឱ្យក្មេងស្រីទៅរស់នៅឆ្ងាយពីគ្រួសារ ។

យេនឌ័រនៅក្នុងវិស័យសុខភាពក៏ជាបញ្ហាប្រឈមមួយដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលនានាកំពុងធ្វើការយកចិត្តទុកដាក់ ដោយខិតខំធ្វើយ៉ាងណាធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពប្រជាពលរដ្ឋទូទៅជាពិសេសដល់ស្ត្រី និងកុមារ ។

អង្កេតប្រជាសាស្ត្រ និងសុខភាពនៅឆ្នាំ២០០៥ បានបង្ហាញថាអត្រាមរណៈមាតាគឺ ៤៧២ នាក់ខ្ពស់ជាងឆ្នាំ ២០០០ ដែលអត្រានេះមាន ៤៣៧ នាក់ ក្នុងចំណោម ១០០.០០០កំណើតរស់ ។ នេះបញ្ជាក់ឱ្យឃើញថាអត្រាមរណៈមាតាមានការផ្លាស់ប្តូរតិចតួចចាប់តាំងពីឆ្នាំ ២០០០ ។ ប៉ុន្តែអត្រាមរណៈទារកបានថយចុះគួរឱ្យកត់សម្គាល់ពី ៩៥ នាក់ នៅឆ្នាំ ២០០០ មកត្រឹមតែ ៦៦ នាក់ នៅឆ្នាំ ២០០៥ ក្នុងចំណោម ១.០០០កំណើតរស់ ។

ពិការភាពរាងកាយមានចំនួន ១.៤៤ ភាគរយនៃប្រជាជនសរុបស្មើនឹង ១៩២.៥៣៨ នាក់ ដែលមានតាំងពីកំណើត ជំងឺដង្កាត់ គ្រាប់មីន គ្រាប់កាំភ្លើង គ្រោះថ្នាក់ចរាចរណ៍ និងគ្រោះថ្នាក់ជាយថាហេតុផ្សេងៗ ( ជំរឿន ២០០៨ ក្នុងនោះស្ត្រីមាន ៤៣.៧ ភាគរយ ស្មើនឹង ៨៤.១៤០ នាក់ ) ។ ស្ថិតិទាំងនេះគឺមិនទាន់រាប់បញ្ចូលពិការភាពផ្នែកសតិបញ្ញា ឬខួរក្បាល និងមានការបែងចែកភេទតិចតួចនៅឡើយ។ ពិការភាពនេះ មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងភាពក្រីក្រ ហើយពិការភាពចំនួន ៥០ ភាគរយអាចបង្ការបាន ។ ទោះជាយ៉ាងណាគម្លាតយេនឌ័រ នៃពួកគេនៅតែរើសអើងទៅលើស្ត្រីដោយពួកគេទទួលបានជំនួយតិចតួចជាងបុរស ( Handicap International Belgium 2006 ) ។

អត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅក្នុងចំណោមមនុស្សពេញវ័យបានថយចុះគួរឱ្យកត់សម្គាល់។ ទោះជាយ៉ាងនេះក្តីអត្រានេះនៅមានកម្រិតខ្ពស់នៅឡើយ។ ទិន្នន័យរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ឆ្នាំ ២០០៧ បង្ហាញថាស្ត្រីពេញវ័យដែលមានអាយុចាប់ពី ១៥-៤៩ឆ្នាំ ចំនួន ១.១ ភាគរយ ក្នុងឆ្នាំ ២០០៦ មានផ្ទុកមេរោគអេដស៍ ។ ស្ត្រីមេម៉ាយប្តីស្លាប់មានអត្រាផ្ទុកមេរោគ អេដស៍ខ្ពស់ជាងគេគឺ ២.៩ ភាគរយ ស្ត្រីមេម៉ាយលែងលះឬរស់នៅដាច់ពីគ្នា មាន ១.១ ភាគរយ និងស្ត្រីរៀបការឬរស់នៅជាមួយគ្នាមាន ០.៧ ភាគរយ ។

តាមរបាយការណ៍បានបង្ហាញពីការកើនឡើងនូវអំពើហិង្សាផ្សេងៗជាច្រើន ដូចជាអំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ( រួមទាំងការរំលោភរបស់ក្រុមក្មេងទំនើង ) អំពើហិង្សាលើនារីធ្វើការបម្រើសេវាកំសាន្តសប្បាយ ការកើនឡើងនូវសេចក្តីរាយការណ៍អំពីស្ត្រី និងកុមារដែលត្រូវបានគេជួញដូរទៅប្រទេសជិតខាង ។ ស្ត្រីចំនួន ២២ ភាគរយ នៃស្ត្រីដែលបានចូលរួមក្នុងការសម្ភាសន៍ បាននិយាយថាខ្លួនបានទទួលអំពើហិង្សាពីប្តីរបស់ខ្លួន ( ក្រសួងកិច្ចការនារី ២០០៨ ) ហើយបុរសចំនួន ១២ ភាគរយ បានរាយការណ៍ថា ខ្លួនបានទទួលអំពើហិង្សាពីប្រពន្ធ ( ក្រសួងកិច្ចការនារី ២០០៥ ) ហើយអំពើហិង្សានេះបានបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមាន លើគ្រួសារទាំងផ្នែកសេដ្ឋកិច្ច រាងកាយ ផ្លូវចិត្ត សុខភាព និងការសិក្សារបស់កូនក្នុងបន្ទុក ។

រាជរដ្ឋាភិបាលមានការរីកចម្រើន ក្នុងការបង្កើតឱ្យមានក្របខ័ណ្ឌច្បាប់សម្រាប់ដោះស្រាយបញ្ហាទាំងនេះ ដោយបាន អនុម័តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ កាលពីថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ក៏ប៉ុន្តែការអនុវត្តច្បាប់នៅមានកម្រិតនៅ ឡើយ ។

នៅក្នុងវិស័យសាធារណៈវិញមន្ត្រីជាស្ត្រីបានកើនឡើងពី ៣១ ភាគរយ ដល់ ៣៤ ភាគរយ ចាប់ពីឆ្នាំ ២០០៦ ដល់ ២០០៩ ។ ប៉ុន្តែភាគច្រើននៃស្ត្រីទាំងនេះមានតួនាទីតូចតាច ដែលសបញ្ជាក់ថាប្រាក់ចំណូលរបស់ពួកគាត់នៅមានកម្រិតទាប ហើយពួកគាត់មានឥទ្ធិពលតិចតួចទៅលើគោលនយោបាយ និងការសម្រេចចិត្តសំខាន់ៗទៀតផង។ នេះបង្ហាញឱ្យឃើញនូវគម្លាត យេនឌ័រនៅក្នុងវិស័យមុខងារសាធារណៈ ដែលតម្រូវឱ្យមានការដោះស្រាយ ។

នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ សមាជិកព្រឹទ្ធសភាជាស្ត្រីបានកើនឡើងពី ១៣ ភាគរយ នៅឆ្នាំ ១៩៩៩ ដល់ ១៤.៨ ភាគរយ នៅឆ្នាំ ២០០៦ ។ ដូចគ្នានេះដែរ នៅក្នុងស្ថាប័នសភាជាតិវិញ អត្រាសមាជិកសភាជាស្ត្រីបានកើនឡើងជាបន្តបន្ទាប់ពីនីតិកាលទី ១ រហូតដល់នីតិកាលទី ៣ គឺពី ៥ភាគរយ ដល់ ១១.៥ ភាគរយ និង ១៩ ភាគរយ ។

នៅក្នុងស្ថាប័ននីតិប្រតិបត្តិវិញ ស្ត្រីត្រឹមតែ ៧.៧ ភាគរយ ប៉ុណ្ណោះដែលមានតួនាទីជារដ្ឋមន្ត្រី ៨.២ ភាគរយ ជារដ្ឋលេខា ធិការ និង ៩.៣ ភាគរយ ជាអនុរដ្ឋលេខាធិការនៅអាណត្តិទី៣នេះ ។

ជាទូទៅ ការចូលរួមរបស់ស្ត្រីនៅក្នុងស្ថាប័ននយោបាយ និងការធ្វើសេចក្តីសម្រេចចិត្តមានការកើនឡើងគួរឱ្យកត់សម្គាល់ ប៉ុន្តែអត្រានេះមានកម្រិតទាបនៅឡើយបើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ ។

## គោលនយោបាយ របស់រដ្ឋាភិបាលចំពោះវិស័យយេនឌ័រ

ក្នុងឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញ ស្តីពីការការពារចំពោះសិទ្ធិរបស់ប្រជាជនខ្មែរដូចមានចែងនៅក្នុងជំពូកទី៣ ដោយរួមបញ្ចូល សង្កត់ធ្ងន់ទៅលើការការពារសិទ្ធិស្ត្រី ។ ការការពារដោយរួមបញ្ចូលទាំងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ( មាត្រា ទី៣១ )និងការហាម ឃាត់ការរើសអើងរាល់ទម្រង់ចំពោះស្ត្រី ( មាត្រាទី៤៦ )។ នេះបានបង្ហាញពីយុទ្ធសាស្ត្រមួយ ដែលរាជរដ្ឋាភិបាលបានកំណត់ជា យុទ្ធសាស្ត្រថ្នាក់ជាតិលើគោលដៅទី៣ នៃការលើកស្ទួយសមភាពយេនឌ័រ និងការផ្តល់សិទ្ធិឱ្យស្ត្រី នៃគោលដៅអភិវឌ្ឍន៍សហស្ស វត្សន៍ប្រទេសកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍជាក់លាក់របស់ប្រជាជន ។ ជាមួយគ្នានេះផងដែរប្រទេសកម្ពុជា ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយនឹងភ្នាក់ងារអន្តរជាតិជាច្រើនលើគោលនយោបាយនេះ។ គណៈកម្មការទប់ស្កាត់រាល់ទម្រង់ នៃការរើសអើងលើស្ត្រី ( CEDAW ) បានអនុវត្តកិច្ចព្រមព្រៀងមួយដែលត្រូវបានផ្តល់សច្ចាប័នតាំងពីឆ្នាំ ១៩៩២ ដើម្បី លើកស្ទួយសមភាពយេនឌ័រនៅក្នុងបរិបទនានាទាំងផ្នែកស៊ីវិល នយោបាយ សេដ្ឋកិច្ចសង្គម និងជីវិតគ្រួសារផងដែរ ។ ដើម្បីធានា លើសមភាពរវាងបុរសនិងស្ត្រីរដ្ឋាភិបាល កំពុងធ្វើការជាដៃគូជាមួយនឹងស្ថាប័ន រដ្ឋធម្មនុញ្ញជាតិ និងអន្តរជាតិដើម្បីរក្សា និង សេចក្តីព្រាងច្បាប់ផ្សេងៗ ដែលទាក់ទងទៅនឹងបទបញ្ជា គោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងសម ភាពយេនឌ័រ ។

# ជំពូកទី ២ ស្ថានភាពទូទៅនៃការងារយេនឌ័ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ២-១ ប្រវត្តិក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានបង្កើតឡើងតាមព្រះរាជក្រម នស/រកម/០១០៥/០០១ ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ និងត្រូវបានដាក់ឱ្យដំណើរការតាមរយៈអនុក្រឹត្យលេខ ៥៥.អនក្រ.បក ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៥ ដោយកំណត់នូវបេសកកម្មក្នុងការដឹកនាំ និងគ្រប់គ្រងវិស័យសង្គមកិច្ច វិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា ។

## ២.២ មុខងារ និងភារកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ដើម្បីសម្រេចបាននូវបេសកកម្មរបស់ខ្លួន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័នផ្សេងៗក្នុងរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការអន្តរជាតិ ព្រមទាំងសង្គមស៊ីវិលនានា និងត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសង្គមកិច្ច និងវិស័យអតីតយុទ្ធជន និងវិស័យយុវនីតិសម្បទា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានមុខងារនិងភារកិច្ចដូចតទៅ :

**ក- វិស័យសង្គមកិច្ច:**

- រៀបចំគោលនយោបាយ និងដឹកនាំ គ្រប់គ្រងរាល់សេវាសង្គមកិច្ចរបស់រដ្ឋ ដើម្បីជួយដល់ប្រភេទជនងាយរងគ្រោះ និង ជនក្រីក្រជាអាទិ៍ ជនចាស់ជរាគ្មានទីពឹង ជនពិការ ជនរស់នៅតាមចិញ្ចើមថ្នល់ កុមារកំព្រា កុមារតាមចិញ្ចើមថ្នល់ ស្រីពេស្យា ជនដែលផ្ទុកមេរោគហ៊ីវ អេដស៍ និងមានមេរោគឆ្លងកាចសាហាវ ជនក្រីក្រជួបការលំបាកជាងគេក្នុងសង្គម
- រៀបចំអនុវត្តគោលនយោបាយ ស្តីពីគ្រួសារ ជនចាស់ជរា
- រៀបចំលិខិតបទដ្ឋាន និងគ្រប់គ្រងការងារ សុំកូនទៅចិញ្ចឹមនៅក្នុង និងក្រៅប្រទេស
- រៀបចំសេវាសង្គមកិច្ច ដើម្បីថែរក្សា ការពារ និងអប់រំ កុមារកំព្រា កុមាររងគ្រោះដោយអំពើជួញដូរដោយជំងឺអេដស៍ កុមារពិការ និង ចិញ្ចឹមបីបាច់ថែរក្សាទារក ដែលត្រូវគេបោះបង់ចោល
- រៀបចំគោលការណ៍គាំពារជនពិការ អនុវត្តការងារស្តារលទ្ធភាពពលកម្ម បង្កលក្ខណៈខាងជីវភាពរស់នៅដល់ជនពិការគ្រប់ប្រភេទ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ ជួយដល់ជនរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ មានគ្រោះថ្នាក់ធម្មជាតិ និងគ្រោះថ្នាក់ផ្សេងៗទៀត
- សហការជាមួយស្ថាប័ន និងអង្គការពាក់ព័ន្ធក្នុងការអនុវត្តសិទ្ធិកុមារ
- គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់មន្ត្រីរាជការតាមការកំណត់របស់ច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល ដែលកំពុងបំពេញភារកិច្ច
- គ្រប់គ្រងរបបធានារ៉ាប់រងសង្គម ដល់កូនកំព្រាពីសពមន្ត្រីរាជការ
- ដឹកនាំគ្រប់គ្រង និងសហការជាដៃគូ ជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដែលធ្វើសកម្មភាពលើវិស័យសង្គមកិច្ចជាអាទិ៍ ការផ្តល់ព័ត៌មាន ការប្រាប់បង្ហាញ ការណែនាំនិងការផ្តល់សេវាសង្គមកិច្ចនានា

- បំផុសការចូលរួមសកម្មភាពសាមគ្គីធម៌សង្គម លើកទឹកចិត្ត និងធ្វើជាដៃគូជាមួយអង្គការមនុស្សធម៌សហគមន៍មូលដ្ឋាន ក្នុងការបង្កើតមូលនិធិទ្រទ្រង់ ដល់សេវាសង្គមកិច្ចនានា ដើម្បីជួយដល់ជនងាយរងគ្រោះគ្រប់ប្រភេទ ។

**ខ- វិស័យអតីតយុទ្ធជនៈ**

- រៀបចំដាក់ឱ្យដំណើរការ សម្របសម្រួលគោលនយោបាយជាតិ ស្តីពីអតីតយុទ្ធជន
- រៀបចំបញ្ចូលអតីតយុទ្ធជន និងគ្រួសារទៅក្នុងសហគមន៍ ដោយលើកកម្ពស់ស្ថានភាពរស់នៅឱ្យបានល្អប្រសើរ និងគ្មានការរើសអើងតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ការដោះស្រាយការងារធ្វើ និងបង្កើតមុខរបរ
- លើកគោលការណ៍អប់រំណែនាំ អតីតយុទ្ធជន ឱ្យយល់ពីតម្លៃកាតព្វកិច្ច តួនាទីក្នុងគ្រួសារ សហគមន៍ និងសង្គម ដើម្បីទទួលបានការអភិវឌ្ឍ
- គ្រប់គ្រងរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារសម្រាប់យោធិន នៃកងយោធពលខេមរភូមិន្ទ តាមការកំណត់របស់ច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- គ្រប់គ្រង និងដោះស្រាយគោលនយោបាយ ជូនជនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន ពិការ និងគ្រួសារនៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពល ដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ ។

**គ- វិស័យយុវនីតិសម្បទាៈ**

- គ្រប់គ្រងក្មេងពីអាយុ៧ឆ្នាំ ដល់ក្រោម១៨ ឆ្នាំ ដែលបានប្រព្រឹត្តបទល្មើស ជនអនាថា អបាយមុខ ក្នុងទូទាំងប្រទេស និងមានតួនាទីកែប្រែអប់រំដើម្បីឱ្យក្លាយទៅជាពលរដ្ឋ
- បង្កើតមណ្ឌលទទួលអប់រំ ដើម្បីឱ្យក្លាយទៅជាពលរដ្ឋល្អ
- បង្កើតមណ្ឌលទទួលអប់រំកុមារ យុវកុមារតាមការចាំបាច់ ដើម្បីទទួលយកកុមារ យុវកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំដើម្បីឱ្យក្លាយទៅជាពលរដ្ឋល្អ
- បង្កើតមណ្ឌលទទួលអប់រំកុមារ យុវកុមារតាមការចាំបាច់ ដើម្បីទទួលយកកុមារ យុវកុមារដែលបានប្រព្រឹត្តអំពើខុសឆ្គងមកគ្រប់គ្រង អប់រំ និងបណ្តុះបណ្តាល
- សហការជាមួយក្រសួង ពាក់ព័ន្ធអង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីអប់រំ បណ្តុះបណ្តាលអនីតិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ បង្កើតកម្មវិធីអប់រំ បណ្តុះបណ្តាលអនីតិជន
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ទណ្ឌិតតាមពន្ធនាគារ
- កសាងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធទៅនឹងការគ្រប់គ្រងវិស័យយុវនីតិសម្បទា
- បង្កើត គ្រប់គ្រងមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## ២-៣ ប្រវត្តិក្រុមការងារយេនឌ័រ

ក្រុមការងារយេនឌ័ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ ២០១០ ក្រោមអនុសាសន៍នៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍នាឆ្នាំ ២០០៥។ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងកិច្ចការនារី ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនេះត្រូវបានរៀបចំឡើងដើម្បីទុកជាឯកសារនាំផ្លូវសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ការសម្រេចបាននូវគោលដៅដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រនេះ គឺជាការរួមចំណែករបស់ក្រសួងក្នុងការអនុវត្តខ្លឹមសារអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ( CEDAW ) និងយោបល់សន្និដ្ឋាន ៤២ ចំណុចរបស់អង្គការសហប្រជាជាតិ ព្រមទាំងបញ្ជាក់នូវការប្តេជ្ញាចិត្តរបស់ក្រសួងក្នុងការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ដោយការងារបញ្ជ្រាបយេនឌ័រកាន់តែមានការមមាញឹក ក្រុមការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានបង្កើតឡើងនៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០ តាមរយៈប្រកាសលេខ ២១៩ ស.អ.យ ដោយក្រុមការងារនេះមានភារកិច្ចជាជំនួយការឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដូចខាងក្រោម :

- រៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ នៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បញ្ជ្រាបសមធមិយេនឌ័រទៅគ្រប់វិស័យការងារជំនាញ ដែលក្រសួងមានបេសកកម្មតាក់តែងឡើង
- កសាងផែនការបញ្ជ្រាបយេនឌ័រប្រចាំឆ្នាំ
- ស្វែងរកការគាំទ្រថវិកា និងបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា ដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រនៃការងារបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យជំនាញ
- ត្រួតពិនិត្យនិងវាយតម្លៃនូវរាល់សកម្មភាពដែលបានអនុវត្តពាក់ព័ន្ធនឹងការងារយេនឌ័រទាំងក្នុងក្របខ័ណ្ឌស្ថាប័នក្រសួង ទាំងក្នុងសកម្មភាពអនុវត្តផែនការក្នុងវិស័យ ។

ដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់រាជរដ្ឋាភិបាល និងធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងអភិបាលកិច្ចល្អ ក៏ដូចជាការធ្វើឱ្យមានកំណើនការងារសមធមិ និងប្រសិទ្ធភាពសេដ្ឋកិច្ច ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្ហាញនូវសមិទ្ធផលសម្រេចបានជាច្រើនតាមរយៈរបាយការណ៍ប្រចាំឆ្នាំ ២០០៩ រួមមានការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្តការអភិវឌ្ឍស្ថាប័នក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ ការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រ ជួយប្រជាជនទន់ខ្សោយជាងគេនៅក្នុងសង្គម បង្កឱកាសឱ្យទទួលបាននូវការឧបត្ថម្ភគាំទ្រទាំងខាងស្មារតី និងសម្ភារៈ ជំរុញការស្តារនីតិសម្បទា និងសមាហរណកម្មក្នុងសង្គមជាតិ ចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងទទួលផ្លែផ្កា នៃការអភិវឌ្ឍប្រកបដោយសមធមិ ។

នៅក្នុងឆ្នាំ ២០០៩ ក្រសួងបានរៀបចំក្របខ័ណ្ឌគោលនយោបាយ និងគតិយុត្តជាច្រើន ដូចជាច្បាប់ គោលនយោបាយ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីណែនាំរួម ប្រកាសរួម សេចក្តីសម្រេច និងបទប្បញ្ញត្តិនានា ក្នុងគោលបំណងពង្រឹងវិស័យសង្គមកិច្ច និងការគ្រប់គ្រងប្រព្រឹត្តទៅដោយភាពរលូន និងអភិបាលកិច្ចល្អ ។

# ជំពូកទី ៣ ការវិភាគយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ខាងក្រោមនេះ គឺជាការវិភាគយេនឌ័រសំខាន់ៗនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ( ស.អ.យ ) ។

## ៣-១ ក្របខ័ណ្ឌច្បាប់គតិយុត្ត និងគោលនយោបាយផ្សេងៗឆ្លើយតបនឹងយេនឌ័រ

ច្បាប់គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទាំងអស់បានយកចិត្តទុកដាក់ និងឆ្លុះបញ្ចាំងនូវបញ្ហាយេនឌ័រ ជាពិសេសបានគិតគូរទៅដល់ក្រុម ដែលងាយរងគ្រោះមានដូចជាស្ត្រី កុមារ និងជនពិការជាដើម។ ក្រសួងស.អ.យ ត្រូវបន្តយកចិត្តទុកដាក់បញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្តថ្មីៗដូចជាច្បាប់ស្តីពីការសុំកូន ច្បាប់ស្តីពី កិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ ព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមអតីតយុទ្ធជន អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល អនុក្រឹត្យស្តីពីរបបគោលនយោ បាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន អនុក្រឹត្យស្តីពីការរៀបចំសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាសកម្មភាពជនពិការ អនុក្រឹត្យស្តីពីការកំណត់អត្រានិងបែបបទជ្រើសរើសជនពិការចូលបម្រើការងារ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ កម្មវិធីការងាររបស់ក្រសួង ស.អ.យ ២០០៨ - ២០១៣ អនុក្រឹត្យស្តីពីការរៀបចំការប្រព្រឹត្តទៅនៃមូលនិធិជនពិការ គោលនយោបាយមនុស្សចាស់ គោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស គោលនយោបាយនិងបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារក្នុងមណ្ឌល និងក្នុងសហគមន៍ ។ នេះបញ្ជាក់ឱ្យឃើញថារាជរដ្ឋាភិបាល ជាពិសេសក្រសួងស.អ.យ បានគិតគូរដល់យេនឌ័រ និងកំពុងត្រូវបានលើកកម្ពស់សមធម៌យេនឌ័រធានានូវសមភាពយេនឌ័រទៅក្នុងវិស័យនីមួយៗ ក៏ដូចជាការបង្កើនការអនុវត្តក្របខ័ណ្ឌច្បាប់ទាំងនោះឱ្យកាន់តែមានប្រសិទ្ធភាព ។ ឧទាហរណ៍ដូចជានៅក្នុង អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលដែលហៅកាត់ថា ប.ជ.ស ក្នុងមាត្រា ១ បានចែងថាអនុក្រឹត្យ នេះមានគោលដៅបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលជាគ្រឹះស្ថានសាធារណរដ្ឋបាល ដើម្បីដាក់ឱ្យដំណើរការគ្រប់គ្រង និងធានាការបើកផ្តល់របបសន្តិសុខសង្គមជូនមន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ។ និងក្នុងមាត្រា ២ បានចែងថា ប.ជ.ស មានវិសាលភាពគ្របដណ្តប់លើមន្ត្រីរាជការស៊ីវិល និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលមានស្ថានភាពចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈក្នុងករណីចូលនិវត្តន៍ បាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារនិងមរណភាព និងអ្នកនៅក្នុងបន្ទុកនៃជនទាំងនេះ នេះបញ្ជាក់ឱ្យឃើញថាអនុក្រឹត្យដែលបានចែងខាងលើនេះមានការគិតគូរដល់ស្ត្រី ជាពិសេសនៅពេលលំហែមាតុភាព ។

## ៣-២ ការវិភាគយេនឌ័រនៅក្នុងកម្រិតស្ថាប័ន

### ៣-២-១ តួនាទីធ្វើសេចក្ដីសម្រេចរបស់ស្ត្រីនៅក្នុងក្រសួង

ផ្អែកតាមប្រភពទិន្នន័យប្រមូលបានដោយក្រុមការងារបញ្ជ្រាបយេនឌ័រ បានបង្ហាញថាមន្ត្រីជាស្ត្រីមានចំនួនត្រឹមតែ ៣៣ ភាគរយប៉ុណ្ណោះនៃចំនួនមន្ត្រីរាជការសរុប ដែលនេះបង្ហាញនូវគម្លាតយេនឌ័រនៅក្នុងតំណាងមន្ត្រីរាជការរបស់ក្រសួង ។

**តារាងបញ្ជីតួនាទីថ្នាក់ដឹកនាំ មន្ត្រី ក្រសួង និងមន្ត្រីថ្នាក់ រាជធានី ខេត្ត និង ក្រុង ស្រុក ខណ្ឌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

| ឋានៈ តួនាទី | ចំនួន | | | ភាគរយ | |
|---|---|---|---|---|---|
| | ប្រុស | ស្រី | ចំនួនសរុប | ប្រុស | ស្រី |
| *ថ្នាក់ដឹកនាំ និងបុគ្គលិកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០១០* | | | | | |
| រដ្ឋមន្ត្រី | ០១ | ០០ | ០១ | ១០០% | ០០ |
| រដ្ឋលេខាធិការ | ០៩ | ០០ | ០៩ | ១០០% | ០០ |
| អនុរដ្ឋលេខាធិការ | ០៧ | ០២ | ០៩ | ៧៧.៧៧ % | ២២.២២% |
| ទីប្រឹក្សា | ១៦ | ០០ | ១៦ | ១០០% | ០០ |
| អគ្គនាយក | ០៣ | ០០ | ០៣ | ១០០% | ០០ |
| អគ្គនាយករង | ១០ | ០០ | ១០ | ១០០% | ០០ |
| ប្រធាននាយកដ្ឋាន | ១៤ | ០៣ | ១៧ | ៨២.៣៥ % | ១៧.៦៤ % |
| អនុប្រធាននាយកដ្ឋាន | ៤៧ | ១៥ | ៦២ | ៧៥.៨០% | ២៤.១៩% |
| ប្រធានការិយាល័យ | ៣០ | ១៦ | ៤៦ | ៦៥.២១% | ៣៤.៧៨% |
| អនុប្រធានការិយាល័យ | ៤១ | ៣៥ | ៧៦ | ៥៣.៩៤% | ៤៦.០៥% |
| បុគ្គលិក | ១៥៨ | ៩៩ | ២៥៧ | ៦១.៤៧ % | ៣៨.៥២% |
| **សរុប** | **៣៣៦** | **១៧០** | **៥០៦** | **៦៦.៤០ %** | **៣៣.៥៩ %** |
| *ថ្នាក់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ* | | | | | |
| ប្រធានមន្ទីរ | ២៤ | ០០ | ២៤ | ១០០ % | ១០០ |
| អនុប្រធានមន្ទីរ | ៧០ | ១៤ | ៨៤ | ៨៣.៣៣% | ១៦.៦៦% |
| ប្រធានការិយាល័យ រាជធានី ខេត្ត | ៨៧ | ២៩ | ១១៦ | ៧៥% | ២៥% |
| អនុប្រធានការិយាល័យ រាជធានី ខេត្ត | ១០៨ | ៧៣ | ១៨១ | ៥៩.៦៦ % | ៤០.៣៣% |
| បុគ្គលិក រាជធានី ខេត្ត | ១២៥ | ១២៥ | ២៥០ | ៥០% | ៥០% |
| ប្រធានការិយាល័យ ក្រុង ស្រុក ខណ្ឌ | ១២៦ | ១២ | ១៣៨ | ៩១.៣០% | ៨.៦៩% |
| អនុប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ | ១២៩ | ៤១ | ១៧០ | ៧៥.៨៨ | ២៤.១១% |
| បុគ្គលិក ក្រុង ស្រុក ខណ្ឌ | ៨១ | ៦១ | ១៤២ | ៥៧.០៤ | ៤២.៩៥% |
| **សរុប** | **៧៩០** | **៣៥៥** | **១ ១០៥** | **៦៧.៨៧ %** | **៣២.១២ %** |

ក្រាហ្វិកទី ១: ភាគរយថ្នាក់ដឹកនាំ មន្ត្រីស្ត្រី និងបុរស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា




*ប្រភព: ក្រុមការងារបញ្ជ្រាបយេនឌ័រ*

ចំណែកនៅក្នុងជួរថ្នាក់ដឹកនាំជាន់ខ្ពស់វិញ មានស្ត្រីតែ ០២ នាក់ប៉ុណ្ណោះ ដែលមានតួនាទីជាអនុរដ្ឋលេខាធិការ ។ ដូចនេះរាល់ ការធ្វើសេចក្តីសម្រេចសំខាន់ៗ ភាគច្រើនគឺធ្វើឡើងដោយបុរស ។

ក្រាហ្វិកទី ២ ខាងក្រោមបង្ហាញថា នៅថ្នាក់កណ្តាល ស្ត្រីមានតំណាងតិចតួចនៅក្នុងគ្រប់តំណែងទាំងអស់ ។ ស្ត្រីគ្មានតំណែងជាអគ្គនាយក និងអគ្គនាយករងទេ ។

**ក្រាហ្វិក ២: តួនាទី ឬតំណែងរបស់មន្ត្រីក្រសួងនៅថ្នាក់កណ្តាល**




*ប្រភព: ក្រុមការងារបញ្ជ្រាបយេនឌ័រ*

ដូចគ្នានេះដែរ នៅថ្នាក់ក្រោមជាតិវិញ ស្ត្រីមានតំណែងតិចតួចប្រៀបធៀបទៅនឹងបុរស។ គ្មានតំណាងស្ត្រីជាប្រធានមន្ទីរទេ ហើយមានស្ត្រីតែ ១៧ ភាគរយប៉ុណ្ណោះជាអនុប្រធានមន្ទីរ។ រីឯប្រធានការិយាល័យ ក្រុង ស្រុក ខណ្ឌ ជាស្ត្រី មានត្រឹមតែ ៩ ភាគរយ ។

**ក្រាហ្វិក ៣: តួនាទី ឬតំណែងរបស់មន្ត្រីក្រសួងនៅថ្នាក់មូលដ្ឋាន**




*ប្រភព: ក្រុមការងារបញ្ជ្រាបយេនឌ័រ*

តំណែងនៅក្នុងថ្នាក់ដឹកនាំមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងកម្រិតអប់រំសិក្សា ខ្វះការគាំទ្រនិងលើកទឹកចិត្តពីថ្នាក់ដឹកនាំ មិនសូវមានស្ត្រីជាបេក្ខជនក្នុងការដាក់ពាក្យចូលជាមន្ត្រី ។ ដូចនេះដើម្បីដោះស្រាយនូវគម្លាតយេនឌ័រនៅក្នុងតួនាទីនេះ ក្រសួងគួរយកចិត្តទុកដាក់ និងលើកទឹកចិត្តបន្ថែមទៀតដល់ស្ត្រី ក្នុងការទទួលបាននូវតួនាទីធ្វើសេចក្តីសម្រេច ក៏ដូចជាការផ្តល់អាទិភាពដល់ស្ត្រីឱ្យបានប្រលងជាប់ជាមន្ត្រីថ្មី ដើម្បីបានចូលរួមកាន់តែច្រើននៅក្នុងការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។ ទន្ទឹមនេះ ស្ត្រីត្រូវព្យាយាមបង្កើនសមត្ថភាពខ្លួនឯង ដើម្បីពង្រឹងពង្រីកឱកាសរបស់ខ្លួនក្នុងការទទួលបាននូវតួនាទីទាំងនេះ ។

## ៣-២-២ ការអភិវឌ្ឍធនធានមនុស្ស

តាមរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាបានបង្ហាញថាក្រសួងបានបញ្ជូនមន្ត្រីជាច្រើននាក់ទៅចូលរួមការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស លើជំនាញផ្សេងៗ ។ មិនតែប៉ុណ្ណោះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងសមត្ថភាពជំនាញដល់មន្ត្រីក្រសួង បានរៀបចំវគ្គបណ្តុះបណ្តាល ផ្នែកសេវាសង្គមកិច្ចមូលដ្ឋាន ( BSST ) ផ្នែកសេវាសង្គមកិច្ចជំនាញ ( PSST ) វគ្គគ្រប់គ្រងសេវាសង្គមកិច្ច ( MSST ) ចិត្តសង្គម ( TPO ) កម្មវិធីវគ្គបំប៉នការងារយល់ដឹងរដ្ឋបាលសង្គមកិច្ច វគ្គបណ្តុះបណ្តាល ស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សដល់មន្ត្រីសង្គមកិច្ច ដើម្បីបង្កើនសមត្ថភាព និងធ្វើឱ្យមានប្រសិទ្ធភាព នូវដំណើរការការពារជនរងគ្រោះវគ្គជំនាញទំនាក់ទំនងថ្នាក់មធ្យម វគ្គបណ្តុះបណ្តាលជំនាញធ្វើបទបង្ហាញពីអាជីព វគ្គបណ្តុះបណ្តាលការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់ ។ ប៉ុន្តែតួលេខនៃអ្នកចូលរួមមិនបានញែកឱ្យដាច់ថា តើមានស្ត្រីប៉ុន្មាននាក់បានចូលរួមការបណ្តុះបណ្តាលជំនាញនីមួយៗឡើយ ។ ទោះជាយ៉ាងនេះក្តី ចំនួនស្ត្រីដែលបានចូលរួមនៅក្នុងការបណ្តុះបណ្តាលទាំងនោះមានចំនួនតិចតួចប៉ុណ្ណោះ។

ទន្ទឹមនឹងនេះទោះបីជាមានការបណ្តុះបណ្តាលជាច្រើនវគ្គហើយក៏ដោយ ទំហំនៃតម្រូវការការបណ្តុះបណ្តាលនៅតែមានច្រើនទាំងលើមុខជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពការងារក៏ដូចជាការបណ្តុះបណ្តាលយេនឌ័រដល់គ្រប់មន្ត្រីទាំងអស់នៅក្នុងក្រសួងជាពិសេសដោយផ្តល់អាទិភាពដល់ស្ត្រី ។

ម្យ៉ាងវិញទៀតការបណ្តុះបណ្តាលយេនឌ័រគួរត្រូវរៀបចំឡើងជាពិសេសសម្រាប់ថ្នាក់ដឹកនាំក្រសួង ដើម្បីទទួលបានការគាំទ្រកាន់តែខ្លាំងនៅក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យនេះ ។

## ៣-៣ ការវិភាគយេនឌ័រនៅក្នុងកម្រិតអ្នកទទួលផលពីសេវាសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

### ៣-៣-១ សេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រងាយរងគ្រោះ

ក្នុងនាមជាសេនាធិការរបស់ក្រសួង នាយកដ្ឋានសុខុមាលភាពសង្គម មានភារកិច្ចសំខាន់ៗដូចជា កម្មវិធីជួយជនអនាថាការពារ ស្តារនីតិសម្បទា និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ កម្មវិធីជួយជនរងគ្រោះ និងជនរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺអេដស៍ កម្មវិធីជំនួយសង្គ្រោះបន្ទាន់សម្រាប់ជនក្រីក្រងាយរងគ្រោះ ការងារគ្រួសារនិងទិវាគ្រួសារនិងការងារដីសម្បទានសង្គមកិច្ច ។

ជាទូទៅស្ត្រី និងកុមារងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស ជាពិសេសការជួញដូរផ្លូវភេទ ។ ដូចនេះដើម្បីទប់ស្កាត់បញ្ហាទាំងនេះក្រសួង ស អ យ ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីក្នុងការ អប់រំផ្សព្វផ្សាយតាមសហគមន៍ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីការជួញដូរមនុស្ស និងការពារទប់ស្កាត់ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព ក៏ដូចជាការរាយការណ៍ពីសកម្មភាពសង្ស័យលើការជួញដូរមនុស្សដល់អាជ្ញាធរមូលដ្ឋានជាដើម ។ លើសពីនេះ ប្រធានបទស្តីពីការទប់ស្កាត់ជំងឺអេដស៍ អំពើហិង្សាក្នុងគ្រួសារ និងច្បាប់ពាក់ព័ន្ធគួរត្រូវបានដាក់បញ្ចូលទៅក្នុងការអប់រំផ្សព្វផ្សាយនេះផងដែរ ។

ចំនួនមណ្ឌលសម្រាប់ទទួលជនរងគ្រោះជាពិសេសស្ត្រី និងកុមារីដោយសារអំពើជួញដូរ និងការផ្តល់សេវាសម្រាប់ជនរងគ្រោះនៅមិនទាន់គ្រប់គ្រាន់នៅឡើយ ដែលទាមទារឱ្យក្រសួងពិនិត្យលទ្ធភាពក្នុងការបង្កើនចំនួនមណ្ឌលថែមទៀត ។ ទាក់ទិននឹងការងារបែងចែកដីសម្បទានសង្គមកិច្ច ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ និងស្ត្រីជាមេគ្រួសារត្រូវបានផ្តល់អាទិភាពក្នុងការទទួលបានដីសម្បទានសង្គមកិច្ច ហើយលក្ខណវិនិច្ឆ័យស្ត្រីទាំងនេះ គួរដាក់បញ្ចូលទៅក្នុងគោលការណ៍ណែនាំ នៃការបែងចែកដីសម្បទានសង្គមកិច្ច ។ ដូចគ្នានេះ ដែរមន្ទីរ ស.អ.យ ត្រូវជួយសម្របសម្រួលដល់ពួកគាត់ដូចជាការពន្យល់ណែនាំអំពីគោលការណ៍ឬការណែនាំក្នុងការបំពេញឯកសារពាក់ព័ន្ធផ្សេងៗជាដើម ។

យោងលើគោលការណ៍បញ្ជ្រាបយេនឌ័រក្នុងការងារបែងចែកដីសម្បទានសង្គមកិច្ច របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានចែងថាបង្កើតនូវការវិភាគយេនឌ័រក្នុងសហគមន៍ ដើម្បីដឹងពីការប្រើប្រាស់ធនធាន ដឹងពីផលប៉ះពាល់លើការរស់នៅរបស់ស្ត្រី និងបុរសក្នុងតំបន់នោះ ដូចជាការរកអនុផលព្រៃឈើ និងការរកឱសថជាដើម ។ ការវិភាគយេនឌ័រនេះធ្វើឡើងដោយការិយាល័យកិច្ចការនារីស្រុក ដែលសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមប្រឹក្សាឃុំ និងក្រុមការងារយេនឌ័ររបស់ក្រសួង ស អ យ រួមជាមួយនឹងក្រសួងកិច្ចការនារី ។ ចំណែកលក្ខណវិនិច្ឆ័យក្នុងការជ្រើសរើស អ្នកដែលត្រូវទទួលបានដីសម្បទានសង្គមកិច្ចត្រូវបានកែប្រែដោយក្រុមប្រឹក្សាឃុំជាអ្នកដាក់ពិន្ទុ គ្រួសារណាដែលមានប្តីចូលចិត្ត បង្កបញ្ហាដូចជាលេងល្បែងស៊ីសង ផឹកសុរា ស្ត្រីមេម៉ាយ ស្ត្រីមេគ្រួសារ ជនពិការ និងជនផ្ទុកមេរោគអេដស៍ នឹងត្រូវបានពិចារណាដោយមិនអាចបង្ខំប្រពន្ធ ឱ្យធ្វើអ្វីតាមបំណងខ្លួនឡើយ ។ តែទោះជាយ៉ាងណាក៏ត្រូវមានការចុះតាមដាន និងត្រួតពិនិត្យ ដើម្បីធានាថាដីដែលបានបែងចែកធ្វើឡើង

ដោយស្របច្បាប់ ។ ការដាក់ពាក្យត្រូវធ្វើឡើងទាំងប្តី និងប្រពន្ធ រាល់ព័ត៌មាននៃការបែងចែកដីត្រូវផ្សព្វផ្សាយតាមផ្ទះ ដើម្បីធានាថាស្ត្រីអាចទទួលបាននូវព័ត៌មានដូចជាបុរសដែរ ។

## ៣-៣-២ សេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា

ចំពោះសេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទាវិញ ក្រសួងមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងនាយកដ្ឋានពីរគឺ នាយកដ្ឋានសុខុមាលភាពកុមារ និងនាយកដ្ឋានយុវនីតិសម្បទា ដែលកំពុងធ្វើការបម្រើសេវាទាំងនេះ ។

នាយកដ្ឋានសុខុមាលភាពកុមារ បាននិងកំពុងធ្វើការជាមួយកុមារងាយរងគ្រោះដូចជាកុមារកំព្រា កុមារពិការ និងកុមាររងគ្រោះផ្សេងទៀត ទាំងនៅក្នុងសហគមន៍ និងនៅតាមមណ្ឌល ក្នុងគោលបំណងលើកកម្ពស់សិទ្ធិសំខាន់ទាំងបួនរបស់កុមារ ។

ផ្អែកតាមរបាយការណ៍ ស្តីពីការចុះអធិការកិច្ចសម្រាប់ការថែទាំជំនួសចំពោះកុមារនៅក្នុងមណ្ឌល ឆ្នាំ ២០០៩ បានបង្ហាញថា មានមណ្ឌលកុមារកំព្រាសរុបចំនួន ២៥៧ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិ និងមាន ២១ មណ្ឌលដែលនៅក្រោមចំណុះរបស់ក្រសួង ដែលមានកុមាររស់នៅចំនួន ១៣ ៨១២ នាក់ ដែលមានកុមារីចំនួន ៥ ៥០៨ នាក់ កុមារា ៨ ៣០៤ នាក់ ។ កន្លងមក មណ្ឌលភាគច្រើនអនុវត្តន៍បានល្អ ប៉ុន្តែមណ្ឌលខ្លះអនុវត្តមិនបានទាំងស្រុងនូវបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារនោះនៅឡើយ ។ ដូចនេះក្រសួងត្រូវបន្តធ្វើការតាមដានជាប់ជាប្រចាំ ដើម្បីធានាថាកុមារនៅតាមមណ្ឌលទទួលបានការថែទាំល្អ និងប្រកបដោយសុវត្ថិភាព និងធានាថាស្ត្រី និង បុរស កុមារី កុមារាទទួលបាននូវតម្រូវការរបស់គេ ។ ម្យ៉ាងវិញទៀត ដើម្បីធានានិរន្តរភាពក្នុងការថែទាំកុមារទាំងនោះគួរតែត្រូវបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដោយមានការតាមដាន និងការជួយឧបត្ថម្ភគ្រប់គ្រាន់ ។

ដូចគ្នានេះដែរ ក្រសួងក៏បានធ្វើការជាមួយកុមារនៅតាមសហគមន៍ ទាំងកុមារងាយរងគ្រោះ និងកុមាររងគ្រោះក្នុងគោលបំណងលើកកម្ពស់សិទ្ធិកុមារ និងផ្តល់កិច្ចការពារដល់កុមារ ។ការលើកកម្ពស់ការយល់ដឹងដល់សហគមន៍អំពីកិច្ចការពារកុមារដល់គ្រប់ស្ថាប័នពាក់ព័ន្ធ ជាពិសេសអាជ្ញាធរមូលដ្ឋាន គឺជាប្រការមួយសំខាន់ដើម្បីឈានសម្រេចជោគជ័យក្នុងការងារនេះ ។ ការអនុវត្តច្បាប់សុំកូន ដែលទើបនឹងត្រូវបានអនុម័តនាពេលថ្មីៗនេះ ក៏ជាផ្នែកមួយរួមចំណែកលើកស្ទួយសិទ្ធិកុមារ និងផ្តល់ការការពារដល់កុមារផងដែរ ។

ទាក់ទិន នឹងការងារយុវនីតិសម្បទាវិញ ក្រសួងកំពុងសហការជាមួយក្រសួងពាក់ព័ន្ធ ដើម្បីជួយដល់កុមារញៀនថ្នាំនិង កុមារដែលទំនាស់នឹងច្បាប់ ទាំងនៅពន្ធនាគារ និងនៅសហគមន៍ ។ បច្ចុប្បន្ននេះក្រសួងមានមណ្ឌលយុវនីតិសម្បទាតិចតួចប៉ុណ្ណោះនៅក្នុងប្រទេសដែលមណ្ឌលទាំងនេះទទួលបានតែមនុស្សប្រុស ។ ក្រសួងគួរពិនិត្យលទ្ធភាព ក្នុងការពង្រីកមណ្ឌលតាមរាជធានី ខេត្ត និងមណ្ឌលដែលអាចទទួលស្ត្រីរងគ្រោះផងដែរ ដើម្បីផ្តល់សេវា ប្រឹក្សាអប់រំ និងការផ្តល់ជំនាញវិជ្ជាជីវៈផ្សេងៗ ។

ដើម្បីរួមចំណែកទប់ស្កាត់នូវបញ្ហាទាំងនេះ ក្រសួងត្រូវសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការផ្សព្វផ្សាយអប់រំតាមសហគមន៍ និងសាលារៀន ដល់កុមារឱ្យយល់ច្បាស់អំពីច្បាប់ និងជាពិសេសយេនឌ័រនិង ផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន មិនតែប៉ុណ្ណោះក្រសួងកំពុងរៀបចំបង្កើតច្បាប់ ស្តីពីយុត្តិធមិអនីតិជន។

## ៣-៣-៣ សេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម

ក្រសួងស.អ.យ បានខិតខំប្រឹងប្រែងយ៉ាងសកម្មនៅក្នុងការលើកកម្ពស់សិទ្ធិជនពិការ តាមរយៈការជំរុញឱ្យមានការ

អនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ដែលបានអនុម័តកាលពីខែកក្កដា ឆ្នាំ២០០៩ ។ ដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ ក៏ដូចជាការស្វែងរកការគាំទ្រមតិពីគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រសួងបានរៀបចំផែនការសកម្មភាពក្នុងការផ្សព្វផ្សាយច្បាប់ឱ្យកាន់តែទូលំទូលាយតាមរយៈសិក្ខាសាលា និងបានបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ការផ្សព្វផ្សាយច្បាប់នេះ ។ ក្រសួងបានផ្តល់អាទិភាពដល់ស្ត្រី ជាពិសេសស្ត្រីពិការឱ្យបានច្រើន ដើម្បីទទួលបានការបណ្តុះបណ្តាលជាគ្រូបង្គោល និងជាជនគំរូដល់គ្រប់ស្ថាប័ន និងមហាជនទូទៅ ។ ម្យ៉ាងទៀតដើម្បីជំរុញការអនុវត្តច្បាប់ ក្រសួងនឹងបន្តរៀបចំជាលិខិតបទដ្ឋាន និងគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងៗទៀត ។ នាយកដ្ឋានជំនាញត្រូវធ្វើការសហការជាមួយក្រុមការងារបញ្ជ្រាបយេនឌ័ររបស់ក្រសួង ដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងលិខិតបទដ្ឋាន និងគោលការណ៍ណែនាំទាំងនោះ ។

ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវាកម្មបម្រើតាមសហគមន៍ ក៏ជាកត្តារួមចំណែកមួយយ៉ាងសំខាន់ដល់ស្ត្រី និងកុមារពិការ ។ ជាទូទៅស្ត្រី និងកុមារត្រូវបានចាត់ទុកថាជាក្រុមងាយរងគ្រោះ ដោយមិនទាន់គិតបញ្ចូលពិការភាពនៅឡើយ ។ ដូចនេះស្ត្រី និងកុមារដែលពិការ កាន់តែមានភាពងាយរងគ្រោះ និងទទួលនូវការរើសអើងខ្លាំងនៅក្នុងសង្គម ដែលនេះទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសដល់ពួកគាត់ ។ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការផ្តល់ឱកាសការងារ និងការទទួលបានសេវាគាំទ្រផ្សេងៗទៀតនៅក្នុងសហគមន៍ គឺជាកត្តាចាំបាច់ ដើម្បីលើកស្ទួយជីវភាពរបស់ពួកគាត់ ក៏ដូចជាឈានទៅរកការលុបបំបាត់ភាពរើសអើងជនពិការនៅក្នុងសង្គម ។ ការពង្រឹងភាពអង់អាចដល់ស្ត្រីពិការ តាមរយៈការចងក្រងក្រុមជួយខ្លួនឯងព្រមទាំងការផ្តល់ការគាំទ្រផ្សេងៗដូចជាការផ្តល់ជំនាញវិជ្ជាជីវៈ ការទទួលសេវាមីក្រូហិរញ្ញវត្ថុ ការជួយទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដើម្បីទទួលបានសេវាផ្សេងៗទៀតជាដើម ។

## ៣-៣-៤ របបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ មន្ត្រីរាជការស៊ីវិល និងប្រជាជនទូទៅ

របបសន្តិសុខសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានតាំងពីរបបរាជ្យកាលព្រះបាទនរោត្តមសុរាម្រិត តាមព្រះរាជក្រឹត្យលេខ ១០ ន.ស ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៥៥ ។ នេះសបញ្ជាក់ពីការយកព្រះទ័យទុកដាក់មកលើប្រជារាស្ត្រខ្មែរ ។ ប៉ុន្តែរបបសន្តិសុខសង្គមនេះ ត្រូវបានបំបាត់ចោលទាំងស្រុងក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ រដ្ឋបាន ផ្តល់នូវការធានារ៉ាប់រងទាំងស្រុងចំពោះជីវភាព និងសុខុមាលភាពរបស់កម្មាភិបាល បុគ្គលិក និងកម្មកររដ្ឋ ហើយបានបង្កើតជារបបសន្តិសុខសង្គម ដោយផ្តល់នូវការធានារ៉ាប់រងសង្គមសម្រាប់កម្មាភិបាល បុគ្គលិក និងកម្មកររដ្ឋដែលក្នុងនោះផ្តល់នូវរបបឧបត្ថម្ភសម្រាប់ការមានជំងឺ គ្រោះថ្នាក់ការងារ សម្រាលកូន មរណភាព និងជួបការលំបាកខ្លាំង ។ បច្ចុប្បន្នអនុវត្តតាមយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលអាណត្តិទី ៣ ត្រង់ចតុកោណទី៣ មុំទី៤ ដែលចែងពីការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់មន្ត្រីបុគ្គលិក កម្មករ និងគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំព្រះរាជក្រឹត្យ ស្តីពីរបបសន្តិសុខសង្គម និងអនុក្រឹត្យ ស្តីពីការបង្កើតរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលគ្របដណ្តប់លើតាវកាលិកចំនួន ៦ គឺ ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក ដែលបច្ចុប្បន្នស្ថាប័ននេះកំពុងរៀបចំយន្តការរបស់ខ្លួនជាបណ្តើរៗ ដោយរៀបចំរចនាសម្ព័ន្ធ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលទាក់ទង នឹងការផ្តល់សេវាឱ្យកាន់តែប្រសើរ តាមគោលការណ៍អភិបាលមានតម្លាភាពប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើការធានារ៉ាប់រងចំពោះប្រជាជនខ្មែរជាពិសេសស្ត្រីដែលក្នុងនោះមន្ត្រីរាជការជាស្ត្រី មានសិទ្ធិឈប់សម្រាកលំហែមាតុភាពរយៈពេល ៣ខែ មុនឬក្រោយសម្រាលកូន និងមានបន្ថែមរបបឧបត្ថម្ភសម្រាលកូនចំនួន ៦០០.០០០រៀល ។ ទន្ទឹមនឹងនោះក្នុងរយៈពេល ១២ ខែក្រោយពេលសម្រាលកូន មានសិទ្ធិឈប់សម្រាក ១ ម៉ោង ក្នុង ១ ថ្ងៃ ។ បន្ថែមពីលើនោះ ស្ត្រីទូទៅដែលមានស្វាមីជាមន្ត្រីរាជការស៊ីវិល

បានទទួលរបបឧបត្ថម្ភចំនួន ៦.០០០ រៀលក្នុង ១ ខែ ទោះបីជាប្តី បានទទួលមរណភាព ក៏នៅអាចទទួលរបបឧបត្ថម្ភដដែល ខុសពីបុរសដោយមិនមានប្រាក់ ឧបត្ថម្ភក្នុងករណីដូចគ្នា ។

ជាមួយគ្នានោះផងដែរ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បាននិងកំពុងរៀបចំអនុក្រឹត្យ ស្តីពីការធានារ៉ាប់រងសុខភាព ដែលជាកត្តាអនុគ្រោះដល់ការកាត់បន្ថយភាពក្រីក្ររបស់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ និងអ្នកនៅក្នុងបន្ទុក ។

## ៣-៣-៥ របបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវការងារដោះស្រាយរបបគោលនយោបាយជូនជនពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ គ្រួសារជនមរណៈ និងគ្រួសារជនពលី ដោយយោងតាមបទដ្ឋានច្បាប់ជាធរមាន។ ដើម្បីបង្កើនប្រសិទ្ធភាព ការផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជនឱ្យកាន់តែប្រសើរ រាជរដ្ឋាភិបាលបាននិងកំពុងបង្កើតនូវបេឡាជាតិអតីតយុទ្ធជន និងរៀបចំនីតិវិធីដើម្បីដាក់ឱ្យដំណើរការការងារនេះឱ្យបានឆាប់នាពេលខាងមុខ ។

ដើម្បីធានានូវតម្លាភាព និងគណនេយ្យភាព ក្នុងការចំណាយថវិកាជាតិ យន្តការនៃការរៀបចំបង្កើតឱ្យមាន មូលដ្ឋានទិន្នន័យរបស់អតីតយុទ្ធជន គឺជាព័ត៌មានចាំបាច់ ក្នុងការគ្រប់គ្រងចំនួនពិតប្រាកដ ក៏ដូចជាបង្កលក្ខណៈងាយស្រួល ក្នុងការលើកផែនការអភិវឌ្ឍន៍ផ្សេងៗ ។

ប៉ុន្តែជាទូទៅស្ត្រីជាគ្រួសាររបស់អតីតយុទ្ធជន ក្លាយជាអ្នកទទួលបន្ទុកដោះស្រាយជីវភាពគ្រួសារ ដែលភាគច្រើនមានជីវភាពមិនសូវធូរធារ ជាស្ត្រីមេម៉ាយ ហើយស្ត្រីដែលជាភរិយា ជាម្តាយ ស្ថិតនៅក្នុងវ័យចាស់គ្មានកម្លាំងគ្រប់គ្រាន់ ដើម្បីបំពេញការងារពលកម្មធ្ងន់ៗនោះទេ ដូចនេះការជួយសម្រាលបន្ទុកដល់គ្រួសារអតីតយុទ្ធជនតាមរយៈការអភិវឌ្ឍ គឺជាប្រការមួយសំខាន់ណាស់ ដើម្បីលើកស្ទួយជីវភាពរបស់ពួកគាត់ ឧទាហរណ៍ការសាងសង់ផ្ទះនៅតាមសហគមន៍ ការកសាងភូមិអតីយុទ្ធជន ការបែងចែកដីឡូសម្រាប់សាងសង់ផ្ទះជូនអតីតកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទពង្រឹងសកម្មភាព និងការបញ្ចូលពួកគេនៅក្នុងការអភិវឌ្ឍ ។

គ្រួសារយុទ្ធជនពលី មរណៈ គួរទទួលការឧបត្ថម្ភផ្នែកថវិកា និងសម្ភារៈឱ្យបានច្រើនដោយហេតុថាស្ត្រីត្រូវក្លាយជាមេគ្រួសារស្វែងរកប្រាក់ចំណូល ដើម្បីចិញ្ចឹមកូនដែលជាទូទៅស្ត្រីទាំងនោះមិនសូវមានជំនាញ និងចំណេះដឹងតិចតួចដើម្បីបំពេញការងារនោះទេ។

## ជំពូកទី ៤ ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០១១-២០១៥

គោលបំណងនៃការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺដើម្បីធានាថាគោលនយោបាយ និងបទដ្ឋានគតិយុត្តនានា បានដាក់បញ្ចូលដល់បញ្ហាយេនឌ័រ និងធានារាល់សេវាកម្មទាំងឡាយត្រូវបានផ្តល់ដល់ជនងាយរងគ្រោះ ជាពិសេសស្ត្រី កុមារ ជនពិការ អតីតយុទ្ធជន និងមនុស្សចាស់ជរា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាក្រសួងមួយដែលមានលក្ខណៈពិសេសដោយហេតុថាបេសកកម្មរបស់ក្រសួង បានធ្វើការរួចជាស្រេចជាមួយក្រុមគោលដៅដែលងាយរងគ្រោះដូចបានរៀបរាប់ខាងដើម ។ ដូចនេះការបន្តអនុវត្តនូវយុទ្ធសាស្ត្រទាំងអស់របស់ក្រសួងដូចបានចែងនៅក្នុងផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ២០០៨-២០១៣ គឺជាការរួមចំណែកលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យនេះ។

ផែនការយុទ្ធសាស្ត្ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបានធានានូវការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ដែលមានដូចខាងក្រោម:

១. បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅក្នុងក្រសួង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២. បង្កើននូវការទទួលបានសេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ

៣. បង្កើនការផ្តល់សេវាសុខុមាលភាពកុមារ និងយុវនីតិសម្បទា

៤. បង្កើនសេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម

៥. ពង្រឹងពង្រីករបបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ និងមន្ត្រីរាជការស៊ីវិល

៦. ពង្រឹងពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន

***យុទ្ធសាស្ត្រទី១: បង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅក្នុងក្រសួង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ***

**គោលបំណងទី១:** បង្កើនសមត្ថភាពរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រ ថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីក្រសួងទាំងមូលលើជំនាញបច្ចេកទេស និងយេនឌ័រ ។

**សកម្មភាព:**

- រៀបចំបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បណ្តុះបណ្តាលក្រុមការងារយេនឌ័រទាំងថ្នាក់កណ្តាល និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អំពីទស្សនទានយេនឌ័រ ការវិភាគយេនឌ័រ និងការធ្វើផែនការ
- ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីទាំងស្ត្រី និងបុរស និងក្រុមការងារយេនឌ័រទាំងថ្នាក់កណ្តាល និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើជំនាញគ្រប់គ្រងភាពជាអ្នកដឹកនាំ រដ្ឋបាល លេខាធិការ ពិធីការ ភាសាអង់គ្លេស និងកុំព្យូទ័រ ។

**សូចនាករ:**

- ចំនួនក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ចំនួនវគ្គបណ្តុះបណ្តាលស្តីអំពីទស្សនទានយេនឌ័រ ការវិភាគយេនឌ័រ និងធ្វើផែនការយេនឌ័រ ដែលបានផ្តល់ឱ្យក្រុមការងារយេនឌ័រថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ចំនួនវគ្គបណ្តុះបណ្តាលលើជំនាញគ្រប់គ្រងភាពជាអ្នកដឹកនាំ រដ្ឋបាល លេខាធិការ ភាសាអង់គ្លេស និងកុំព្យូទ័រ ដែលផ្តល់ដល់មន្ត្រីជាស្ត្រី និងបុរស និងក្រុមការងារបញ្ជ្រាបយេនឌ័រ ក្នុងក្រសួង ស.អ.យ ។

**គោលបំណងទី២:** បង្កើនឱ្យមានការគាំទ្រមតិ និងការចូលរួមពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ។

**សកម្មភាព:**

- រៀបចំសិក្ខាសាលាវេទិកាពិភាក្សាលើការលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងវិស័យស.អ.យ
- ផ្តល់ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីថ្នាក់កណ្តាល អំពីយេនឌ័រក្នុងវិស័យស.អ.យ
- រៀបចំប្រារព្ធទិវា៨មិនាដោយបញ្ចូលសារសំខាន់ៗ ទាក់ទងនឹងយេនឌ័រដើម្បីបង្កើនការគាំទ្រពីថ្នាក់ដឹកនាំ
- បញ្ចូលរបៀបវារៈ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ ក្នុងវេទិកាថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ និងទៅក្នុងកិច្ចប្រជុំក្រុមការងារពហុវិស័យ
- គ្រប់កិច្ចប្រជុំថ្នាក់ដឹកនាំ ឬសន្និបាតប្រចាំឆ្នាំ ត្រូវមានបញ្ចូលរបៀបវារៈ នៃការលើកកម្ពស់សមភាពយេនឌ័រ ។

**សូចនាករ:**

- ចំនួនសិក្ខាសាលាវេទិកាពិភាក្សាលើការលើកកម្ពស់ សមភាពយេនឌ័រ ក្នុងវិស័យស.អ.យ ដែលបានរៀបចំ
- ចំនួនអ្នកចូលរួមក្នុងសិក្ខាសាលាវេទិកាពិភាក្សា លើការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យស.អ.យ
- ចំនួនវគ្គបណ្តុះបណ្តាលអំពីយេនឌ័រក្នុងវិស័យស.អ.យ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីថ្នាក់កណ្តាល
- ចំនួនពិធីនៃការប្រារព្ធទិវា៨មិនាត្រូវបានបញ្ចូលសារសំខាន់ៗទាក់ទងនឹងយេនឌ័រ
- ចំនួនវេទិកាថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះកិច្ចប្រជុំក្រុមការងារពហុវិស័យ ដែលបានបញ្ចូលរបៀបវារៈ ស្តីពីការលើកកម្ពស់យេនឌ័រ
- ចំនួនសកម្មភាពកិច្ចប្រជុំថ្នាក់ដឹកនាំសំខាន់ៗ ឬសន្និបាតប្រចាំឆ្នាំ ក្នុងក្រសួងស.អ.យ ដែលបានបញ្ចូលរបៀបវារៈ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ ។

**គោលបំណងទី ៣:** ផ្តល់ឱកាសដល់ស្ត្រីក្នុងការទទួលបាន ការតែងតាំង ឬដំឡើងឋានៈ ។

**សកម្មភាព:**

- អនុវត្តប្រព័ន្ធកូតាជ្រើសរើសដល់ស្ត្រីឱ្យបានជាប់ជាមន្ត្រីថ្មីពី ៣០% ទៅ ៥០%
- បញ្ចូលសមាជិកក្រុមការងារយេនឌ័រទៅក្នុងគណៈកម្មាការប្រឡងជ្រើសរើសបុគ្គលិក
- រៀបចំគោលការណ៍តែងតាំងឱ្យឆ្លើយតបនឹងយេនឌ័រ ។

**សូចនាករ:**

- មានប្រព័ន្ធកូតាជ្រើសរើសដល់ស្ត្រីឱ្យជាប់ជាមន្ត្រីថ្មី
- ភាគរយនៃស្ត្រីដែលជាប់ជាមន្ត្រីថ្មី
- ចំនួនសមាជិកក្រុមការងារយេនឌ័រ ជាគណៈកម្មាការប្រឡងជ្រើសរើសបុគ្គលិក
- ចំនួនលិខិតតតិយុត្តតែងតាំង ដែលមានស្ត្រីចូលរួម ។

***យុទ្ធសាស្ត្រទី២: បង្កើនទូវការផ្តល់សេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ជាពិសេសដល់ស្ត្រីក្រីក្រស្ត្រីមេគ្រួសារ***

**គោលបំណងទី ១:** បង្ការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ។

**សកម្មភាព:**

- លើកកម្ពស់ការយល់ដឹងអំពីការជួញដូរស្ត្រីនិងកុមារ និងជំងឺអេដស៍ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះរួមមានស្ត្រីក្រីក្រ ស្ត្រីជាមេគ្រួសារ
- ទិវា ១៥ឧសភាស្តីពីគ្រួសារ ត្រូវបានប្រារព្ធនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដោយបញ្ចូលរបៀបវារៈយេនឌ័រ

- បណ្តុះបណ្តាលដល់មន្ត្រីទាំងស្ត្រី បុរសនៃក្រសួងស.អ.យ ស្តីពី គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

**សូចនាករ:**

- ចំនួនគ្រួសារក្រីក្រ និងងាយរងគ្រោះរួមមានស្ត្រីក្រីក្រ ស្ត្រីមេគ្រួសារដែលយល់ដឹងអំពីការជួញដូរស្ត្រី កុមារ និងជំងឺអេដស៍
- ទិវា១៥ឧសភាព ស្តីពីគ្រួសារដោយមានបញ្ចូលរបៀបវារៈយេនឌ័រ
- ចំនួនមន្ត្រីដែលបានទទួលវគ្គបណ្តុះបណ្តាល ស្តីពី គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ចំនួនមន្ត្រីជាស្ត្រីដែលបានបណ្តុះបណ្តាល ។

**គោលបំណងទី ២ :** ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ

**សកម្មភាព:**

- សហការជាមួយស្ថាប័នពាក់ព័ន្ធផ្តល់ជំនួយទាន់ពេលវេលាដល់ជនរងគ្រោះដោយយកចិត្តទុកដាក់ដល់តម្រូវការស្ត្រី និងកុមារ
- អប់រំស្ត្រី និងកុមារអំពីគ្រោះថ្នាក់មហន្តរាយ និងវិធីដំណោះស្រាយទប់ទល់ ។

**សូចនាករ:**

- ចំនួនកញ្ចប់សង្គ្រោះដែលបានផ្តល់ឱ្យជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ដោយសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ
- ចំនួនគ្រួសារដែលមានស្ត្រី និងកុមារបានទទួលកញ្ចប់សង្គ្រោះ
- ចំនួនវគ្គបណ្តុះបណ្តាលស្តីអំពី គ្រោះមហន្តរាយ និងវិធីដំណោះស្រាយទប់ទល់សម្រាប់ស្ត្រី និង កុមារ

**គោលបំណងទី៣:** សម្របសម្រួលដល់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីមេគ្រួសារ គ្រួសារយុទ្ធជនពលី និងពិការក្នុងការទទួលបានដីសម្បទានសង្គមកិច្ច និងតម្រូវការស្ត្រី ក្នុងការប្រើប្រាស់ដីសម្បទានសង្គមកិច្ច ។

**សកម្មភាព:**

- ជួយផ្តល់ព័ត៌មាន និងធ្វើការផ្សព្វផ្សាយដល់ស្ត្រីឱ្យបានយល់ច្បាស់ការបែងចែកដីធ្លី
- ជួយសម្របសម្រួល និងណែនាំដល់ស្ត្រី ជាពិសេសស្ត្រីដែលមិនអាចអាន និងសរសេរអក្សរបាន ក្នុងការបំពេញបែបបទ
- លក្ខខណ្ឌនៃការបែងចែកដីធ្លីត្រូវដាក់ផ្តល់អាទិភាពដល់គ្រួសារយុទ្ធជនពលី និងពិការ ស្ត្រីមេគ្រួសារ និងស្ត្រីក្រីក្រ ។

**សូចនាករ:**

- ចំនួនវគ្គផ្សព្វផ្សាយអំពីវិធានការក្នុងការទទួលបានដីសង្គមកិច្ចដល់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីជាមេគ្រួសារ
- មានការណែនាំដល់ស្ត្រីងាយរងគ្រោះ ក្នុងការបំពេញបែបបទ
- លក្ខខណ្ឌនៃការបែងចែកដីធ្លី មានបញ្ចូលគ្រួសារយុទ្ធជនពលី ពិការ ស្ត្រីមេគ្រួសារ និងស្ត្រីក្រីក្រជាអាទិភាព ។

**គោលបំណងទី ៤:** បង្កើនចំនួនមណ្ឌលសំចត និងសេវាផ្សេងៗ ( បណ្តុះបណ្តាលវិជ្ជាជីវៈ កាត់ដេរ អ៊ុតសក់ ) ដល់ស្ត្រីក្រីក្រ ស្ត្រីមេគ្រួសារ ។

**សកម្មភាព:**

- សង់មណ្ឌលសំចត និង ផ្តល់សេវាផ្សេងៗ ដូចជាបណ្តុះបណ្តាលវិជ្ជាជីវៈ ( កាត់ដេរ កាត់ដេរម៉ូត អ៊ុតសក់ សម្អាងកាយ ធ្វើនំម្ហូប ជួសជុលម៉ូតូ )ដល់ស្ត្រីក្រីក្រី ស្ត្រីជាមេគ្រួសារ និងគ្រួសារក្រីក្រ ។

**សូចនាករ:**

- ចំនួនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីក្រីក្រ ស្ត្រីជាមេគ្រួសារ និងគ្រួសារក្រីក្រ
- ចំនួនស្ត្រីក្រីក្រ និងស្ត្រីជាមេគ្រួសារដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**គោលបំណងទី ៥:** ផ្តល់សេវាសង្គមកិច្ចដល់ជនងាយរងគ្រោះ និងរងគ្រោះដោយសារអំពើជួញដូរ ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារ តាមរយៈការផ្តល់កន្លែងស្នាក់នៅតាមសហគមន៍ ដោយមានការថែទាំ ។

**សកម្មភាព:**

- ផ្តល់ការផ្សព្វផ្សាយ ស្តីពីសេវាសង្គមកិច្ចដល់ជនងាយរងគ្រោះ និងរងគ្រោះ ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារ នៅតាមសហគមន៍
- ផ្តល់វគ្គបណ្តុះបណ្តាល អំពីគោលនយោបាយនៃការការពារសិទ្ធិជនរងគ្រោះដោយការជួញដូរ ដល់បុគ្គលិកសង្គមកិច្ច ក្រុមប្រឹក្សាឃុំ ជាពិសេសជនបង្គោលដែលទទួលបន្ទុកស្ត្រី និង កុមារ និងស្ថាប័នសង្គមស៊ីវិលនានា ។

**សូចនាករ:**

- ចំនួនដងនៃការផ្សព្វផ្សាយ ស្តីពីសេវាសង្គមកិច្ចដល់ជនងាយរងគ្រោះ និងរងគ្រោះ ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារនៅតាមសហគមន៍
- ចំនួនអ្នកចូលរួម ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារ ដែលជាជនងាយរងគ្រោះ និងរងគ្រោះ នៅតាមសហគមន៍
- ភាគរយកន្លែងស្នាក់នៅតាមសហគមន៍ ដែលបានធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្តល់សេវា បន្ទាប់ពីការវាយតម្លៃ ។

***យុទ្ធសាស្ត្រទី ៣: បង្កើនការផ្តល់សេវាសុខុមាលភាពកុមារ ជាពិសេសកុមារី និងយុវនីតិសម្បទាទាំងបុរស និង ស្ត្រី***

**គោលបំណងទី១:** ពង្រឹងការអនុវត្តបទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ នៅតាមមណ្ឌល និងសហគមន៍ ជាពិសេសកុមារី ។

**សកម្មភាព:**

- គ្រប់គ្រងទិន្នន័យបែងចែកភេទកុមារកំព្រានៅតាមមណ្ឌលរបស់រដ្ឋនិងមណ្ឌលរបស់អង្គការ និងនៅតាមសហគមន៍
- បើកវគ្គបំប៉ន ស្តីពីការត្រួតពិនិត្យការអនុវត្តបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងសម្រង់ស្ថិតិ កុមារាកុមារីនៅតាមមណ្ឌល និងសហគមន៍ ។

**សូចនាករ:**

- ភាគរយកុមារីកំព្រាដែលទទួលការថែទាំនៅតាមមណ្ឌលរដ្ឋ អង្គការ និងសហគមន៍
- ចំនួនវគ្គបំប៉ន ស្តីពីការត្រួតពិនិត្យការអនុវត្តបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងស្ថិតិកុមារាកុមារីដែលទទួលការថែទាំនៅតាមមណ្ឌល និងសហគមន៍ ។

**គោលបំណងទី ២ :** ពង្រឹងសមត្ថភាពសហគមន៍ដើម្បីចូលរួមលើកកម្ពស់សិទ្ធិកុមារ និងផ្តល់កិច្ចការពារដល់កុមារីនិងកុមារា ។

**សកម្មភាព:**

- បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សហគមន៍ មន្ត្រីមានសមត្ថកិច្ច អាជ្ញាធរដែនដី និងមាតា បិតា ដើម្បីចូលរួមលើកកម្ពស់សិទ្ធិកុមារ និងការពារកុមារ ដោយមានការទទួលខុសត្រូវយេនឌ័រ
- លើកកម្ពស់ការចូលរួមរបស់ស្ត្រី និងកុមារី កុមារា ក្នុងសកម្មភាពសហគមន៍ ។

**សូចនាករ:**

- ចំនួនវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងការពារកុមារដល់សហគមន៍ មន្ត្រីមានសមត្ថកិច្ច អាជ្ញាធរដែនដី និងមាតា បិតា ដោយមានការទទួលខុសត្រូវយេនឌ័រ
- ចំនួនកុមារី កុមារា និងស្ត្រីដែលបានចូលរួម ។

**គោលបំណងទី ៣: បង្កើនសេវាស្តារនីតិសម្បទា ដល់ស្ត្រីពិការ ។**

**សកម្មភាព :**

- សាងសង់មណ្ឌលសម្រាប់ស្ត្រីរងគ្រោះ
- ផ្តល់សេវាប្រឹក្សានិងជំនាញវិជ្ជាជីវៈ ដល់ស្ត្រីពិការ
- អប់រំផ្សព្វផ្សាយតាមសហគមន៍ និងសាលារៀនអំពីច្បាប់យុត្តិធម៌ អនីតិជន គ្រឿងញៀន ជំងឺអេដស៍ ដល់សហគមន៍ និងសាលារៀនដោយមានការទទួលខុសត្រូវយេនឌ័រ ។

**សូចនាករ:**

- ចំនួនមណ្ឌលស្ត្រីរងគ្រោះដែលបានសាងសង់បន្ថែម
- ចំនួនស្ត្រីរងគ្រោះដែលបានទទួលសេវាប្រឹក្សា និងផ្តល់ជំនាញវិជ្ជាជីវៈ
- ចំនួនវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់អនីតិជន គ្រឿងញៀន និង ជំងឺអេដស៍ដល់សហគមន៍ និងសាលារៀនដោយមានការទទួលខុសត្រូវយេនឌ័រ
- ចំនួនស្ត្រី និងបុរសក្នុងសហគមន៍ ដែលបានទទួល វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយ ។

***យុទ្ធសាស្ត្រទី ៤: បង្កើនសេវាសុខុមាលភាពជនពិការ ជាពិសេសស្ត្រី និង កុមារីពិការ និងស្តារលទ្ធភាពពលកម្ម***

**គោលបំណងទី ១:** លើកកម្ពស់សុខុមាលភាពជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងស្តារលទ្ធភាពពលកម្ម ឱ្យកាន់តែប្រសើរឡើង ។

**សកម្មភាព:**

- ជ្រើសរើសស្ត្រី និងស្ត្រីពិការជាគ្រូបង្គោល ដើម្បីបង្កើនការផ្សព្វផ្សាយច្បាប់
- បញ្ជ្រាបយេនឌ័រទៅក្នុងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ
- ស្វែងរកការគាំទ្រពីគ្រប់ស្ថាប័ន ដើម្បីបង្កើនការយកចិត្តទុកដាក់ដល់ជនពិការ ជាពិសេសសម្រាប់ស្ត្រី និងកុមារី ។

**សូចនាករ:**

- ចំនួនស្ត្រីពិការជាគ្រូបង្គោល
- ចំនួនដងនៃការផ្សព្វផ្សាយច្បាប់
- លិខិតបទដ្ឋានគតិយុត្តមានការបញ្ជ្រាបយេនឌ័រ
- ចំនួនស្ថាប័ន និងដៃគូដែលបានគាំទ្រ ។

**គោលបំណងទី ២ :** បង្កើនសេវាសុខុមាលភាពដល់ស្ត្រី និងកុមារីពិការ ។

**សកម្មភាព :**

- ចងក្រងក្រុមជួយខ្លួនឯងដោយមានការចូលរួមពីស្ត្រីឱ្យបានទូទាំងប្រទេស
- ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី និងកុមារីពិការ
- សម្របសម្រួលជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល ជាតិនិងអន្តរជាតិ ដើម្បីទទួលបានសេវាមីក្រូហិរញ្ញវត្ថុ និងសេវាគាំទ្រផ្សេងៗទៀត ។

**សូចនាករ:**

- ចំនួនក្រុមស្ត្រីចូលរួមក្នុងក្រុមជួយខ្លួនឯង
- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី និងកុមារីពិការ
- សេវាមីក្រូហិរញ្ញវត្ថុ និងសេវាគាំទ្រផ្សេងៗត្រូវបានផ្តល់ឱ្យជនពិការ ជាពិសេសស្ត្រីនិងកុមារីពិការ ។

**គោលបំណងទី ៣:** រៀបចំចងក្រងទិន្នន័យស្ត្រី និងកុមារីពិការ ។

**សកម្មភាព:**

- សហការជាមួយក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃក្នុងការប្រមូលទិន្នន័យស្ត្រី និងកុមារីពិការទូទាំងប្រទេស ។

**សូចនាករ:**

- ទិន្នន័យស្ត្រី និងកុមារីពិការ ។

***យុទ្ធសាស្ត្រទី ៥: ពង្រឹងពង្រីករបបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ និងមន្ត្រីរាជការស៊ីវិលដោយមានការទទួលខុសត្រូវយេនឌ័រ***

**គោលបំណងទី ១ :** ធានាបើកផ្តល់របបសន្តិសុខឱ្យបានទាន់ពេលវេលា មានប្រសិទ្ធភាព តម្លាភាព និងដោយមានការទទួលខុសត្រូវយេនឌ័រ ។

***សកម្មភាព:***

- លើកគម្រោងផែនការថវិកាឱ្យបានម៉ត់ចត់ទាន់ពេលវេលា
- រៀបចំសំណុំបែបបទក្នុងការស្នើសុំប្រាក់របបសន្តិសុខសង្គមឱ្យបានឆាប់រហ័ស
- ជំរុញការបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ លុបបំបាត់ការទិញ និងលក់របប និងបំបាត់ភាពអសកម្មនានា ។

**សូចនាករ:**

- ទិន្នន័យមន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល
- មានគម្រោងផែនការថវិកាទាន់ពេលវេលា
- មានសំណុំបែបបទ ក្នុងការស្នើសុំប្រាក់របបសន្តិសុខសង្គម ។

**គោលបំណងទី ២:** លើកកម្ពស់សុខុមាលភាពមន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ជាពិសេសស្ត្រី

***សកម្មភាព:***

- លើកគម្រោងផែនការថវិកាឱ្យបានម៉ត់ចត់ទាន់ពេលវេលា
- រៀបចំសំណុំបែបបទក្នុងការស្នើសុំប្រាក់របបសន្តិសុខសង្គមឱ្យបានឆាប់រហ័ស
- ជំរុញការបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ
- លុបបំបាត់ការទិញ លក់របប និងបំបាត់ភាពអសកម្មនានា ។

**សូចនាករ:**

- លិខិតបទដ្ឋានគតិយុត្ត ក្នុងការកសាងរចនាសម្ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រង ការផ្តល់ធានារ៉ាប់រងសុខភាពដោយការទទួលខុសត្រូវយេនឌ័រ
- ចំនួនក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍដែលបានសហការ ។

**គោលបំណងទី ៣ :** រៀបចំយន្តការដើម្បីឱ្យមានបេឡាឥណទានសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល និងអនុគ្រោះការប្រាក់កាន់តែទាបបំផុតសម្រាប់ស្ត្រី ។

***សកម្មភាព:***

- បង្កើតបេឡាឥណទានសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ដោយបញ្ចូលការប្រាក់ទាបបំផុតសម្រាប់ស្ត្រី។

**សូចនាករ:**

- មានបេឡាឥណទានសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ដែលបញ្ចូលការប្រាក់ទាបបំផុតសម្រាប់ស្ត្រី ។

**គោលបំណងទី ៤ :** កែសម្រួលរបបគោលនយោបាយសម្រាប់មន្ត្រីរាជការ និងអតីតមន្ត្រីរាជការស៊ីវិល ជាពិសេសសម្រាប់ស្ត្រី និងកុមារ ។

***សកម្មភាព:***

- លើកសំណើការកែសម្រួលរបបគោលនយោបាយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ សិក្សាវាយតម្លៃ និងសម្រេច ។

**សូចនាករ:**

- របបគោលនយោបាយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ សិក្សាវាយតម្លៃ និងសម្រេច ។

**គោលបំណងទី ៥ :** ពង្រឹងការគាំទ្រ និងការយកចិត្តទុកដាក់ដល់ជនចាស់ជរា ជាពិសេសស្ត្រីចូលរួមក្នុងផលប្រយោជន៍សង្គម ដែលអាចឱ្យជនចាស់ជរាជួយខ្លួនឯងផង និងសង្គមជាតិផង ។

**សកម្មភាព:**

- បង្កើនការផ្សព្វផ្សាយពីសារៈសំខាន់ នៃបញ្ហារបស់មនុស្សចាស់ ការការពារសិទ្ធិរបស់ជនចាស់ជរាជាពិសេស ស្ត្រីនៅតាមសហគមន៍ដាច់ស្រយាល

- ធ្វើការវិភាគយេនឌ័រ ក្នុងការស្រាវជ្រាវ ការធ្វើផែនការ ការវាយតម្លៃសកម្មភាពសម្រាប់ជនចាស់ជរា ។

**សូចនាករ:**

- ចំនួនការផ្សព្វផ្សាយពីសារៈសំខាន់ នៃបញ្ហារបស់មនុស្សចាស់ និងការការពារសិទ្ធិរបស់ជនចាស់ជរា ជាពិសេសស្ត្រីនៅតាមសហគមន៍ដាច់ស្រយាល

- របាយការណ៍ការវិភាគយេនឌ័រ ក្នុងការស្រាវជ្រាវ ការធ្វើផែនការ ការវាយតម្លៃសកម្មភាពសម្រាប់ជនចាស់ជរា ។

**គោលបំណងទី ៦:** ផ្តល់ធានារ៉ាប់រងសង្គមជូនប្រជាពលរដ្ឋទូទៅទាំងស្ត្រី និង បុរស ។

**សកម្មភាព:**

- ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រងលើការផ្តល់ធានារ៉ាប់រងសង្គម សម្រាប់ប្រជាពលរដ្ឋទូទៅដែលជាកត្តាអនុគ្រោះដល់ជនងាយរងគ្រោះជាពិសេសស្ត្រី និងកុមារ ។

**សូចនាករ:**

- ចំនួនលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងលើការផ្តល់ធានារ៉ាប់រងសង្គមសម្រាប់ប្រជាពលរដ្ឋទូទៅ ដែលជាកត្តាអនុគ្រោះដល់ជនងាយរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ។

***យុទ្ធសាស្ត្រទី ៦: ពង្រឹងពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន ដោយមានការទទួលខុសត្រូវយេនឌ័រ***

**គោលបំណងទី ១:** ពង្រឹងការអភិវឌ្ឍអតីតយុទ្ធជនដោយផ្តល់អាទិភាព ពិសេសដល់គ្រួសារយុទ្ធជនពលី មរណៈ និងពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជាពិសេសស្ត្រីមេគ្រួសារ ដែលមានជីវភាពក្រីក្រលំបាកជាងគេ ។

**សកម្មភាព:**

- បែងចែកដីលំនៅឋាន និងដីសម្បទានសង្គមកិច្ចសម្រាប់បង្កបង្កើនផលដល់គ្រួសារយុទ្ធជនពលីមរណៈ និងពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ ជាពិសេសស្ត្រីមេគ្រួសារ

- សម្របសម្រួលជាមួយស្ថាប័នពាក់ពន្ធ័ដើម្បីបង្កើនវិជ្ជាជីវៈ ជំនាញកសិកម្ម ដល់ស្ត្រីដែលជាសមាជិកគ្រួសារអតីតយុទ្ធជន

- សម្របសម្រួលក្នុងការទទួលបានសេវាមីក្រូហិរញ្ញវត្ថុសម្រាប់ស្ត្រីនៅក្នុងគ្រួសារអតីតយុទ្ធជន ។

**សូចនាករ:**

- ចំនួនគ្រួសារយុទ្ធជនពលី មរណៈ និងពិការ និវត្តជន ជនបាត់បង់សមត្ថភាពការងារ គ្រួសារដែលមានស្ត្រីជាមេគ្រួសារទទួលបានផ្ទះដីលំនៅឋាន និងដីសម្បទានសង្គមកិច្ច
- ជំនាញវិជ្ជាជីវៈ ជំនាញកសិកម្ម សេវាមីក្រូហិរញ្ញវត្ថុ ត្រូវបានផ្តល់ដល់ស្ត្រីដែលជា សមាជិកគ្រួសារអតីតយុទ្ធជន ។

**គោលបំណងទី ២:** លើកកម្ពស់វិស័យអតីតយុទ្ធជន ជាពិសេសគ្រួសារជនពលី មរណៈ ពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ ជាពិសេសស្ត្រីជាមេគ្រួសារ ។

**សកម្មភាព:**

- រៀបចំរបបសន្តិសុខសង្គម ដល់ស្ត្រីជាជនពិការនៅពេលសម្រាលកូន
- រៀបចំគោលការណ៍ដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុកម្តាយ អាណាព្យាបាលរបស់ជនពលីមរណៈ
- រៀបចំគោលការណ៍កែសម្រួលបន្ថែមប្រាក់ម្ហូបជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការ ទាំងបុរស និងស្ត្រី ។

**សូចនាករ:**

- មានគោលការណ៍ផ្តល់របបសន្តិសុខសង្គមដល់ជនពិការ ជាស្ត្រីនៅពេលសម្រាលកូនគ្រប់គ្នា
- មានគោលការណ៍ដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុកម្តាយ និងអាណាព្យាបាល
- មានគោលការណ៍កែសម្រួលបន្ថែមប្រាក់ម្ហូប ជូននិវត្តជន ជនបាត់បង់សមត្ថភាពការងារ និងជនពិការទាំងបុរស និងស្ត្រី
- មានគោលការណ៍ផ្តល់ប្រាក់បន្ថែម ជូនមន្ត្រីរាជការស៊ីវិល ។

# ឧបសម្ព័ន្ធ

១. គោលការណ៍ណែនាំសម្រាប់ក្រុមការងារយេនឌ័រនៅតាមក្រសួងពាក់ព័ន្ធនានា

២. សមាជិកភាពក្រុមការងារយេនឌ័រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣. ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០១១-២០១៥

៤. បញ្ជីត្រួតពិនិត្យសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី ឬ គម្រោង

៥. វាក្យសព្ទបច្ចេកទេសយេនឌ័រ

## ឧបសម្ព័ន្ធ១៖គោលការណ៍ណែនាំសម្រាប់ក្រុមការងារយេនឌ័រនៅតាមក្រសួងពាក់ព័ន្ធនានា

### ១. សមាជិកភាពរបស់ក្រុម

ប្រធាន : រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ( បើអាចគួរជាសមាជិករបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី )

អនុប្រធាន : អគ្គនាយក ឬអគ្គនាយករង

សមាជិក : ១រូប ពីគ្រប់នាយកដ្ឋាន

<u>សមាជិកក្នុងក្រុមគួរមាន:</u>

- តុល្យភាពរវាងបុរស និងស្ត្រី
- ចំណេះដឹង សមត្ថភាព និងជំនាញ នៅក្នុងក្រសួង ជាពិសេសពាក់ព័ន្ធនឹងស្ត្រី
- សុឆន្ទៈក្នុងការបង្កើនសមធម៌យេនឌ័រ ទៅក្នុងគោលនយោបាយ កម្មវិធី និងការគ្រប់គ្រង
- ការយល់ដឹងជាមូលដ្ឋាន ពីគោលគំនិតនៃការបញ្រ្ជាបយេនឌ័រ
- តួនាទីដែលអាចមានឥទ្ធិពល និងអាចស្វែងរកការគាំទ្រសម្រាប់ការបញ្រ្ជាបយេនឌ័រ
- ជំនាញក្នុងការរៀបចំកម្មវិធី និងផែនការ
- សមត្ថភាពជាអ្នកស្វែងរកការគាំទ្រមតិ សម្រាប់បញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងការអនុវត្តជាក់ស្តែង
- បញ្ចូលជនបង្គោលយេនឌ័រ និងមន្ត្រីដែលធ្វើការងារបញ្ជ្រាបយេនឌ័រ ក្នុងពេលបច្ចុប្បន្ននៅតាមក្រសួងនីមួយៗ។

**<u>កំណត់ចំណាំ:</u>** រាល់សមាជិកនីមួយៗនៅក្នុងក្រុម មិនចាំបាច់មានគ្រប់លក្ខណវិនិច្ឆ័យដូចបានរៀបរាប់ខាងលើនេះទេ ប៉ុន្តែនៅក្នុងក្រុមទាំងមូលត្រូវតែមានលក្ខណវិនិច្ឆ័យទាំងអស់នេះ។

### ២. ភារកិច្ចសំខាន់ៗ

- ធ្វើការពិនិត្យទៅលើកម្មវិធី និងសកម្មភាពតាមវិស័យនីមួយៗ វិភាគរកផលប៉ះពាល់ និងឥទ្ធិពលរបស់សកម្មភាពទាំងអស់នេះទៅលើបុរស ស្ត្រី
- ពិនិត្យ និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ លើកម្មវិធី និងគម្រោងថ្មីៗ ក្នុងក្រសួងរបស់គេ
- ពិនិត្យលើស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីនៅក្នុងក្រសួង និងស្ថាប័នរបស់ពួកគេ និងផ្តល់អនុសាសន៍សម្រាប់លើកកម្ពស់ស្ត្រីទៅក្នុងតួនាទីធ្វើសេចក្តីសម្រេច
- រៀបចំសេចក្តីព្រាងគោលនយោបាយ និងផែនការសកម្មភាពបញ្ជ្រាបយេនឌ័រសម្រាប់សាមីក្រសួង
- បញ្ជូនតំណាងចូលរួមក្នុងក្រុមការងារតាមវិសយ័នីមួយៗ ដើម្បីស្វែងរកការគាំទ្រមតិលើបញ្ហាយេនឌ័រ ព្រមទាំងជាសមាជិកក្រុមការងារបច្ចេកទេសយេនឌ័រ
- ចូលរួមក្នុងការធ្វើផែនការ និងកម្មវិធីនៅក្នុងក្រសួង ដើម្បីធានាថាផែនការនិងកម្មវិធីទាំងនោះមានការឆ្លើយតបនឹងយេនឌ័រ
- បង្កើនចំណេះដឹងពីទស្សនៈ និងគោលគំនិតយេនឌ័រ និងស្វែងរកការគាំទ្រមតិ ដើម្បីឱ្យកម្មវិធី និងសកម្មភាពនានានៅក្នុងក្រសួងមានភាពឆ្លើយតបនឹងយេនឌ័រ
- កៀរគរធនធានជាតិសម្រាប់ការបញ្ជ្រាបយេនឌ័រ

## ឧបសម្ព័ន្ធ ២: សមាជិកភាពក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

មានសមាសភាពសរុបចំនួន ១៨ រូប ដែលក្នុងនោះមានស្ត្រី ចំនួន ១១ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ០១ - ឯកឧត្តម | **ឈាង ធាក់** | អនុរដ្ឋលេខាធិការក្រសួង | ប្រធាន |
| ០២ - ឯកឧត្តម | **ថ្លាក់ ចាន់ធឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស | អនុប្រធាន |
| ០៣ - លោកស្រី | **ស៊ិន សារឿន** | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | សមាជិក |
| ០៤ - លោកស្រី | **គឹម សុផុន** | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | សមាជិកអចិន្ត្រៃយ៍ |
| ០៥ - លោក | **សោម សំអឿន** | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | សមាជិក |
| ០៦ - លោកស្រី | **ថេម សិខាមណី** | អធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ០៧ - លោកស្រី | **ញៀប សុភាព** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ | សមាជិក |
| ០៨ - លោកស្រី | **ជ័យ ណារ៉ាត្រី** | អនុប្រធាននាយកដ្ឋានសោធននិវត្តន៍ | សមាជិក |
| ០៩ - លោក | **សារត សុផល** | អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម | សមាជិក |
| ១០ - លោកស្រី | **ម៉ូ ស៊ីថា** | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ១១ - លោក | **ម៉ូ សុខាឌី** | អនុប្រធាននាយកដ្ឋានយុវនីតិសម្បទា | សមាជិក |
| ១២ - លោកស្រី | **និន កន្និដ្ឋា** | អនុប្រធាននាយកដ្ឋានសោធនអតីតយុទ្ធជន | សមាជិក |
| ១៣ - លោក | **ពេជ្រ កុសល** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន | សមាជិក |
| ១៤ - លោកស្រី | **ស៊ាន ម៉ូលីន** | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប | សមាជិក |
| ១៥ - លោក | **ថោង ម៉ិនណា** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៦ - កញ្ញា | **ឡាំ សុខន** | ប្រធានការិ នាយកដ្ឋានសុខុមាលភាពសង្គម | សមាជិក |
| ១៧- លោកស្រី | **អ៊ុំ សោគ៌ណា** | ប្រធានការិ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១៨ -លោកស្រី | **ឃឹម សុបំណាង** | ប្រធានការិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ៣០៧ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារយេនឌ័ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញ អនុក្រឹត្យ លេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងលិខិតរបស់ក្រសួងកិច្ចការនារីលេខ ៣៧៨ ក ន ន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥ ស្តីពីគោលការណ៍ណែនាំ និងភារកិច្ចតួនាទីចម្បងៗ របស់ក្រុមការងារយេនឌ័រនៅក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល
- ពិនិត្យឃើញការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារយេនឌ័ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១ - ឯកឧត្តម | **ឈាង ឆាក់** | អនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋានសុខុមាលភាពសង្គម | ជាប្រធាន |
| ២ - ឯកឧត្តម | **ថ្រាក់ ចាន់ធឿន** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស | អនុប្រធាន |
| ៣ - លោកស្រី | **ស៊ិន សារ៉ោន** | ប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | សមាជិក |

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

| | | | | |
|---|---|---|---|---|
| ៤ - លោកស្រី | ឥម | សុផុន | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | សមាជិកអចិន្ត្រៃយ៍ |
| ៥ - លោក | សោម | សំអឿន | អនុប្រធាននាយកដ្ឋានសុខុមាលភាពសង្គម | សមាជិក |
| ៦ - លោកស្រី | ថេម | សិខាមណី | អធិការ នៃអគ្គាធិការដ្ឋាន | សមាជិក |
| ៧ - លោកស្រី | ញៀប | សុភាព | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ | សមាជិក |
| ៨ - លោកស្រី | ជ័យ | ណាត្រី | អនុប្រធាននាយកដ្ឋានសោធននិវត្តន៍ | សមាជិក |
| ៩ - លោក | សាត | សុផល | អនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម | សមាជិក |
| ១០ - លោកស្រី | ម៉ី | ស៊ីថា | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ១១ - លោក | ម៉ី | សុខាឌី | អនុប្រធាននាយកដ្ឋានយុវនីតិសម្បទា | សមាជិក |
| ១២ - លោកស្រី | និន | ភន្និដ្ឋា | អនុប្រធាននាយកដ្ឋានសោធនអតីតយុទ្ធជន | សមាជិក |
| ១៣ - លោក | ពេជ្រ | កុសល | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍អតីតយុទ្ធជន | សមាជិក |
| ១៤ - លោកស្រី | ស៊ីន | ប៉ូលីន | អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប | សមាជិក |
| ១៥ - លោក | ថោង | ម៉ុនណ្ណា | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៦ - លោកស្រី | ឃីម | សុបំណាច | ប្រធានការិយាល័យអាស៊ាន នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១៧ - កញ្ញា | ព្រុំ | សុខន | ប្រធានការិយាល័យសេវាទប់ស្កាត់ និងការពារជនអនាថា នាយកដ្ឋានសុខុមាលភាពសង្គម | សមាជិក |
| ១៨ - លោកស្រី | អ៊ុំ | សោភ័ណ្ឌ | ប្រធានការិយាល័យបៀវត្ស នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក | សមាជិក |

**ប្រការ ២.-**

ក្រុមការងារនេះ មានភារកិច្ចជំនួយការឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចខាងក្រោម:

១ - រៀបចំគោលនយោបាយ និងផែនការសកម្មភាពបញ្រ្ជាបយេនឌ័ររបស់ក្រសួង

២ - ចូលរួមពិនិត្យកម្មវិធី និងសកម្មភាពតាមវិស័យនីមួយៗ និងវិភាគរកផលប៉ះពាល់ និងឥទ្ធិពល នៃសកម្មភាពទាំងនោះទៅលើបុរស ស្ត្រី

៣ - ចូលរួមក្នុងការធ្វើផែនការ និងកម្មវិធីនៅក្នុងក្រសួង ដើម្បីធានាថាផែនការ និងកម្មវិធីទាំងនោះមានការឆ្លើយតបទៅនឹងយេនឌ័រ

៤ - ចូលរួមពិនិត្យ និងផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងបញ្ហាយេនឌ័រលើកម្មវិធី និងគម្រោងថ្មីៗរបស់ក្រសួង

៥ - ពិនិត្យស្ថានភាពបច្ចុប្បន្នរបស់ស្ត្រីនៅក្នុងក្រសួង និងផ្តល់អនុសាសន៍ សម្រាប់លើកកម្ពស់ស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេច

៦ - បង្កើនចំណេះដឹងពីទស្សនៈ និងគោលគំនិតយេនឌ័រ និង ស្វែងរកការគាំទ្រមតិ ដើម្បីឱ្យកម្មវិធី និងសកម្មភាពនានានៅក្នុងក្រសួងមានការឆ្លើយតបទៅនឹងយេនឌ័រ

៧ - កៀរគរ ស្វែងរកប្រភពជំនួយឧបត្ថម្ភគាំទ្រពីអង្គការជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការបញ្រ្ជាបយេនឌ័រ ។ ៗ

**ប្រការ ៣.-**

នាយកដ្ឋានសុខុមាលភាពសង្គម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាទីស្នាក់ការអចិន្ត្រៃយ៍សម្រាប់ក្រុមការងារនេះ ។

**ប្រការ ៤.-**

សមាជិកក្រុមការងារ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៦.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃ អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានទាំងអស់ក្រោមឱវាទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងឯកឧត្តម អស់លោក លោកស្រី ដូចមានឈ្មោះក្នុងប្រការ ១ មានភារកិច្ចអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងកិច្ចការនារី
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៣: ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០១១-២០១៥

**យុទ្ធសាស្ត្រទី ១: បង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងតួនាទីធ្វើសេចក្តីសម្រេចនៅក្នុងក្រសួង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

| គោលបំណង | សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុកឆ្នាំ ២០១៥ |
|---|---|---|---|
| ១- បង្កើនសមត្ថភាពរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិង មន្ត្រីក្រសួងទាំងមូលលើជំនាញបច្ចេកទេស និងយេនឌ័រ | - រៀបចំបង្កើតក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | - ចំនួនក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | - ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានបង្កើតឡើង និងមានការប្រជុំទៀងទាត់ ដើម្បីពិភាក្សាលើប្រធានបទយេនឌ័រ |
| | - បណ្តុះបណ្តាលក្រុមការងារយេនឌ័រទាំងថ្នាក់កណ្តាល និងរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ អំពីទស្សនទានយេនឌ័រ ការវិភាគយេនឌ័រ និងការធ្វើផែនការ | - ចំនួនវគ្គបណ្តុះបណ្តាលស្តីអំពីទស្សនៈទានយេនឌ័រ ការវិភាគយេនឌ័រ និងធ្វើផែនការយេនឌ័រ ដែលបានផ្តល់ឱ្យក្រុមការងារយេនឌ័រ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | - ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានការយល់ដឹងពីទស្សនទានយេនឌ័រ ការវិភាគយេនឌ័រ និងការធ្វើផែនការ |
| | - ផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីទាំងស្ត្រី និងបុរស និងក្រុមការងារយេនឌ័រទាំងថ្នាក់កណ្តាល និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើជំនាញគ្រប់គ្រងភាពជាអ្នកដឹកនាំ រដ្ឋបាល លេខាធិការ ពិធីការ ភាសាអង់គ្លេស និងកុំព្យូទ័រ | - ចំនួនវគ្គបណ្តុះបណ្តាលលើជំនាញគ្រប់គ្រងភាពជាជាអ្នកដឹកនាំ ភាសាអង់គ្លេស និងកុំព្យូទ័រ ដែលផ្តល់ដល់មន្ត្រីជាស្ត្រី និងបុរស និងក្រុមការងារបញ្ជ្រាបយេនឌ័រក្នុងក្រសួង ស.អ.យ | - ចំណេះដឹងលើភាសាអង់គ្លេស កុំព្យូទ័រ និងភាពជាអ្នកដឹកនាំរបស់ក្រុមការងារបញ្ជ្រាបយេនឌ័រថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីជាស្ត្រីនិងបុរសត្រូវបានកើនឡើង |

| | | | |
|---|---|---|---|
| ២- បង្កើនឱ្យមានការគាំទ្រមតិ និងការចូលរួមពីថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ | - រៀបចំសិក្ខាសាលា វេទិកាពិភាក្សាលើការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងវិស័យស.អ.យ<br>- ផ្តល់ការបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីកណ្តាលអំពីយេនឌ័រក្នុងវិស័យស.អ.យ<br>- រៀបចំប្រារព្ធទិវាជមិនាដោយបញ្ចូលសារសំខាន់ៗទាក់ទងនឹងយេនឌ័រដើម្បីបង្កើនការគាំទ្រពីថ្នាក់ដឹកនាំ<br>- បញ្ចូលរបៀបវារៈស្តីពីការលើកកម្ពស់សមភាពយេនឌ័រ ក្នុងវេទិកាថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ និងទៅក្នុងកិច្ចប្រជុំក្រុមការងារពហុវិស័យ<br>- គ្រប់កិច្ចប្រជុំថ្នាក់ដឹកនាំ ឬសន្និបាតប្រចាំឆ្នាំ ត្រូវមានបញ្ចូលរបៀបវារៈនៃការលើកកម្ពស់សមភាពយេនឌ័រ | - ចំនួនសិក្ខាសាលាវេទិកាពិភាក្សាលើការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យស.អ.យដែលបានរៀបចំ<br>- ចំនួនអ្នកចូលរួមក្នុងសិក្ខាសលាវេទិកាពិភាក្សាលើការលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យស.អ.យ<br>- ចំនួនវគ្គបណ្តុះបណ្តាលអំពីយេនឌ័រក្នុងវិស័យស.អ.យ ដល់ថ្នាក់ដឹកនាំ និងមន្ត្រីថ្នាក់កណ្តាល<br>- ចំនួនពិធីនៃការប្រារព្ធទិវាជមិនាត្រូវបានបញ្ចូលសារសំខាន់ៗទាក់ទងនឹងយេនឌ័រ<br>- ចំនួនវេទិកាថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ កិច្ចប្រជុំក្រុមការងារពហុវិស័យ ដែលបានបញ្ចូលរបៀបវារៈ ស្តីពីការលើកកម្ពស់យេនឌ័រ<br>- ចំនួនសកម្មភាពកិច្ចប្រជុំថ្នាក់ដឹកនាំសំខាន់ៗ ឬសន្និបាតប្រចាំឆ្នាំ ក្នុងក្រសួងស.អ.យ ដែលបានបញ្ចូលរបៀបវារៈ ស្តីពីការលើកកម្ពស់សមភាពយេនឌ័រ | - ថ្នាក់ដឹកនាំគ្រប់កម្រិត និងមន្ត្រីថ្នាក់កណ្តាលមានចំណេះដឹងយេនឌ័រនៅក្នុងវិស័យស.អ.យ និងតែងយកចិត្តទុកដាក់គិតគូរដល់បញ្ហាយេនឌ័រនៅពេលបំពេញការងារនិងបញ្ចូលទៅក្នុងគម្រោងផែនការនានាក្នុងក្រសួង |

| | | | |
|---|---|---|---|
| ៣- ផ្តល់ឱកាសដល់ស្ត្រីក្នុងការទទួលបានការតែងតាំង ឬដំឡើងឋានៈ | - អនុវត្តប្រព័ន្ធកូតាជ្រើសរើសដល់ស្ត្រីឱ្យបានជាប់ជាមន្ត្រីថ្មីពី ៣០% ទៅ ៥០%<br>- បញ្ចូលសមាជិកក្រុមការងារយេនឌ័រទៅក្នុងគណៈកម្មាការប្រឡងជ្រើសរើសបុគ្គលិក<br>- រៀបចំគោលការណ៍តែងតាំងឱ្យឆ្លើយតបនឹងយេនឌ័រ | - មានប្រព័ន្ធកូតាជ្រើសរើសដល់ស្ត្រីឱ្យជាប់ជាមន្ត្រីថ្មី<br>- ភាគរយនៃស្ត្រីដែលជាប់ជាមន្ត្រីថ្មី<br>- ចំនួនសមាជិកក្រុមការងារយេនឌ័រ ជាគណៈកម្មាការ ប្រឡងជ្រើសរើសបុគ្គលិក<br>- ចំនួនលិខិតគតិយុត្តតែងតាំង ដែលមានស្ត្រីចូលរួម | - ភាគរយមន្ត្រីជាស្ត្រីបានកើនពី ៣៣%ដល់៥០%<br>- ចំនួនស្ត្រីដែលបានដំឡើងឋានៈបានកើនឡើង |
| **យុទ្ធសាស្ត្រទី ២: បង្កើននូវការផ្តល់សេវាសុខុមាលភាពសង្គមសម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ជាពិសេសដល់ស្ត្រីក្រីក្រ ស្ត្រីមេគ្រួសារ** | | | |
| **គោលបំណង** | **សកម្មភាព** | **សូចនាករ** | **លទ្ធផលរំពឹងទុកឆ្នាំ ២០១៥** |
| ១- បង្ការទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ | - លើកកម្ពស់ការយល់ដឹងអំពីការជួញដូរស្ត្រីនិងកុមារ និងជំងឺអេដស៍ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ រួមមានស្ត្រីក្រីក្រ ស្ត្រីមេគ្រួសារ<br>- ទិវា ១៥ ឧសភាស្តីពីគ្រួសារ ត្រូវបានប្រារព្ធនៅថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ដោយបញ្ចូលរបៀបវារៈយេនឌ័រ<br>- បណ្តុះបណ្តាលមន្ត្រីទាំងស្ត្រី និងបុរសនៃក្រសួង ស.អ.យ អំពីគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ | - ចំនួនគ្រួសារក្រីក្រ និងងាយរងគ្រោះរួមមានស្ត្រីក្រីក្រ ស្ត្រីមេគ្រួសារដែលយល់ដឹងអំពីការជួញដូរស្ត្រី និងកុមារ និងជម្ងឺអេដស៍<br>- ទិវា ១៥ ឧសភាពស្តីពីគ្រួសារដោយមានបញ្ចូលរបៀបវារៈយេនឌ័រ<br>- ចំនួនមន្ត្រីដែលបានទទួលវគ្គបណ្តុះបណ្តាលស្តីពីគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស<br>- ចំនួនមន្ត្រីជាស្ត្រីដែលទទួលការបណ្តុះបណ្តាល | - ជនរងគ្រោះ និងជនងាយរងគ្រោះមាន ជីវភាពប្រសើរឡើង<br>- ការជួញដូរស្ត្រី និង កុមារត្រូវបានថយចុះ |
| ២- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ប្រជាជនក្រីក្រងាយរងគ្រោះ ដោយមានការទទួលខុសត្រូវយេនឌ័រ | - សហការជាមួយស្ថាប័នពាក់ព័ន្ធផ្តល់ជំនួយទាន់ពេលវេលាដល់ជនរងគ្រោះដោយយកចិត្តទុកដាក់ដល់តម្រូវការស្ត្រី និងកុមារ | - ចំនួនកញ្ចប់សង្គ្រោះដែលបានផ្តល់ឱ្យជនរងគ្រោះ ជាពិសេសស្ត្រី និងកុមារ ដោយសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ | - ស្ត្រីនិងកុមារទទួលបានជំនួយទាន់ពេលវេលា<br>- ស្ត្រីនិងកុមារមានវិធានការសម្រាប់ទប់ទល់គ្រោះមហន្តរាយ |

| | | | |
|---|---|---|---|
| | - អប់រំស្ត្រី និងកុមារអំពីគ្រោះមហន្តរាយ និងវិធីសាស្ត្រដោះស្រាយទប់ទល់ | - ចំនួនគ្រួសារដែលមានស្ត្រី និងកុមារបានទទួលកញ្ចប់សង្គ្រោះ<br>- ចំនួនវគ្គបណ្តុះបណ្តាលស្តីអំពីគ្រោះមហន្តរាយ និងវិធីសាស្ត្រដោះស្រាយទប់ទល់សម្រាប់ស្ត្រី និងកុមារ | |
| ៣- សម្របសម្រួលដល់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីមេគ្រួសារ គ្រួសារយុទ្ធជនពលី និងពិការក្នុងការទទួលបានដីសម្បទានសង្គមកិច្ច និងតម្រូវការស្ត្រី ក្នុងការប្រើប្រាស់ដីសម្បទានសង្គមកិច្ច | - ជួយផ្តល់ព័ត៌មាន និងធ្វើការផ្សព្វផ្សាយដល់ស្ត្រីឱ្យបានយល់ច្បាស់អំពីការបែងចែកដីធ្លី<br>- ជួយសម្របសម្រួល និងណែនាំដល់ស្ត្រីជាពិសេសស្ត្រីដែលមិនអាចអាន និងសរសេរអក្សរបានក្នុងការបំពេញបែបបទ<br>- លក្ខខណ្ឌនៃការបែងចែកដីធ្លីត្រូវផ្តល់អាទិភាពដល់គ្រួសារយុទ្ធជនពលី និងពិការ ស្ត្រីមេគ្រួសារ និងស្ត្រីក្រីក្រ | - ចំនួនវគ្គផ្សព្វផ្សាយអំពីវិធានការក្នុងការទទួលបានដីសង្គមកិច្ច ដល់ស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីជាមេគ្រួសារ<br>- មានការណែនាំដល់ស្ត្រីងាយរងគ្រោះ ក្នុងការបំពេញបែបបទ<br>- លក្ខខណ្ឌនៃការបែងចែកដីធ្លី ត្រូវបានផ្តល់អាទិភាពគ្រួសារយុទ្ធជនពលី ពិការ ស្ត្រីមេគ្រួសារ និងស្ត្រីក្រីក្រ | - ចំនួនស្ត្រីក្រីក្រ ស្ត្រីមេម៉ាយ ស្ត្រីជាមេគ្រួសារ គ្រួសារយុទ្ធជនពលី និងពិការដែលបានទទួលដីសម្បទានសង្គមកិច្ចកើនឡើង |
| ៤- បង្កើនចំនួនមណ្ឌលសំចតនិងសេវាផ្សេងៗ( បណ្តុះបណ្តាលវិជ្ជាជីវៈ ( កាត់ដេរ អ៊ុតសក់...)ដល់ស្ត្រីក្រីក្រ ស្ត្រីមេគ្រួសារ | - សង់មណ្ឌលសំចត និងផ្តល់សេវាផ្សេងៗ ដូចជាបណ្តុះបណ្តាលវិជ្ជាជីវៈ ( កាត់ដេរ កាត់ដេរម៉ូតអ៊ុតសក់ សម្អាងកាយ ធ្វើនំ ម្ហូប ជុសជុលម៉ូតូ......) ដល់ស្ត្រីក្រីក្រ ស្ត្រីជាមេគ្រួសារ និងគ្រួសារក្រីក្រ | - ចំនួនវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ( កាត់ដេរ កាត់ដេរម៉ូតអ៊ុតសក់ សម្អាងកាយ ធ្វើនំ ម្ហូប ជុសជុលម៉ូតូ ...... ) ដល់ស្ត្រីក្រីក្រ ស្ត្រីជាមេគ្រួសារ និងគ្រួសារក្រីក្រ<br>- ចំនួនស្ត្រីក្រីក្រ និងស្ត្រីជាមេគ្រួសារដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជាកាត់ដេរ និងអ៊ុតសក់ | - ជីវភាពរបស់ស្ត្រីក្រីក្រ និងស្ត្រីជាមេគ្រួសារ និងគ្រួសារក្រីក្រ ដែលបានបណ្តុះបណ្តាលមានភាពប្រសើរឡើង |
| ៥- ផ្តល់សេវាសង្គមកិច្ច ដល់ជនងាយរងគ្រោះ និងរងគ្រោះដោយការជួញដូរ ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារ តាមរយៈការផ្តល់កន្លែងស្នាក់នៅតាមសហគមន៍ ដោយមានការថែទាំ | - ផ្តល់ការផ្សព្វផ្សាយ ស្តីពីសេវាសង្គមកិច្ចដល់ជនងាយរងគ្រោះ និងរងគ្រោះ ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារ នៅតាមសហគមន៍ | - ចំនួនដងនៃការផ្សព្វផ្សាយ ស្តីពីសេវាសង្គមកិច្ចដល់ជនងាយរងគ្រោះ និងរងគ្រោះ ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេគ្រួសារ នៅតាមសហគមន៍<br>- ចំនួនអ្នកចូលរួម ជាពិសេសស្ត្រីក្រីក្រ និងស្ត្រីមេ | - ជនងាយរងគ្រោះ និងជនរងគ្រោះ ជាពិសេសស្ត្រីក្រីក្រ និង ស្ត្រីជាមេគ្រួសារនៅតាមសហគមន៍យល់ដឹងពីសេវាសង្គមកិច្ចនិងធ្វើឱ្យជីវិតប្រសើរឡើង |

| | | | |
|---|---|---|---|
| | - ផ្តល់វគ្គបណ្តុះបណ្តាល អំពីគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរ ដល់បុគ្គលិកសង្គមកិច្ចក្រុមប្រឹក្សាឃុំ ជាពិសេសជនបង្គោលដែលទទួលបន្ទុកស្ត្រី និងកុមារ និងស្ថាប័នសង្គមស៊ីវិលនានា | គ្រួសារ ដែលជាជនងាយរងគ្រោះ និងរងគ្រោះនៅតាមសហគមន៍<br>- ភាគរយកន្លែងស្នាក់នៅតាមសហគមន៍ ដែលបានធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផ្តល់សេវា បន្ទាប់ពីការវាយតម្លៃ | - មានប្រព័ន្ធផ្តល់សេវាប្រកបដោយគុណភាព<br>- គ្រប់កន្លែងស្នាក់នៅ អនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយការជួញដូរ<br>- សិទ្ធិរបស់ជនរងគ្រោះ ដោយការជួញដូរត្រូវបានការពារ<br>- គ្រប់ជនរងគ្រោះអាចប្រើប្រាស់សេវាសង្គម |

**យុទ្ធសាស្ត្រទី ៣៖ បង្កើនការផ្តល់សេវាសុខុមាលភាពកុមារ ជាពិសេសកុមារី និងយុវនីតិសម្បទាទាំងបុរស និង ស្ត្រី**

| គោលបំណង | សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុកឆ្នាំ ២០១៥ |
|---|---|---|---|
| ១- ពង្រឹងការអនុវត្តបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ នៅតាមមណ្ឌលកុមារកំព្រា និងសហគមន៍ ជាពិសេសកុមារី | - គ្រប់គ្រងទិន្នន័យបែងចែកភេទកុមារកំព្រានៅតាមមណ្ឌលរបស់រដ្ឋនិងមណ្ឌលរបស់អង្គការនិងនៅតាមសហគមន៍ | - ភាគរយកុមារីកំព្រាដែលទទួលការថែទាំនៅតាមមណ្ឌលរដ្ឋ អង្គការ និងសហគមន៍ | - ការអនុវត្តបទដ្ឋានអប្បបរមា នៅតាមមណ្ឌលកុមារត្រូវបានពង្រឹង និងកុមារីនៅតាមមណ្ឌលទទួលបានសេវាថែទាំងប្រកបដោយគុណភាព |
| | - បើកវគ្គបំប៉នស្តីពីការត្រួតពិនិត្យការអនុវត្តបទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងស្ថិតិកុមារាកុមារីនៅតាមមណ្ឌល និងសហគមន៍ | - ចំនួនវគ្គបំប៉នស្តីពីការត្រួតពិនិត្យការអនុវត្តបទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ និងស្ថិតិកុមារាកុមារីដែលទទួលការថែទាំនៅតាមមណ្ឌល និងសហគមន៍ | |

| | | | |
|---|---|---|---|
| ២- ពង្រឹងសមត្ថភាពសហគមន៍ដើម្បីចូលរួមលើកកម្ពស់សិទ្ធិកុមារ និងផ្តល់កិច្ចការពារដល់កុមារី និងកុមារា | - បណ្តុះបណ្តាល និងផ្សព្វផ្សាយដល់សហគមន៍ មន្ត្រីមានសមត្ថកិច្ច អាជ្ញាធរដែនដី និងមាតាបិតា ដើម្បីចូលរួមលើកកម្ពស់សិទ្ធិកុមារ និងការពារកុមារ ដោយមានការទទួលខុសត្រូវយេនឌ័រ<br>- លើកកម្ពស់ការចូលរួមរបស់ស្ត្រី និងកុមារី កុមារា ក្នុងសកម្មភាពសហគមន៍ | - ចំនួនវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងការពារកុមារ ដល់សហគមន៍ មន្ត្រីមានសមត្ថកិច្ច អាជ្ញាធរដែនដី និងមាតាបិតា ដោយមានការទទួលខុសត្រូវយេនឌ័រ<br>- ចំនួនកុមារី កុមារា និងស្ត្រីដែលបានចូលរួម | - សហគមន៍ មន្ត្រីមានសមត្ថកិច្ច អាជ្ញាធរដែនដី និងមាតាបិតាមានការយល់ដឹងនិងចូលរួមលើកកម្ពស់សិទ្ធិកុមារ និងការពារកុមារ ដោយមានការទទួលខុសត្រូវយេនឌ័រ<br>- ស្ត្រី កុមារី និងកុមារាមានការយល់ដឹងពីសិទ្ធិកុមារ និងមានវិធានការការពារខ្លួន |
| ៣- បង្កើនការផ្តល់សេវាស្តារនីតិសម្បទា ដល់ស្ត្រីពិការ | - សាងសង់មណ្ឌលសម្រាប់ស្ត្រីរងគ្រោះ<br>- ផ្តល់សេវាប្រឹក្សា និងជំនាញវិជ្ជាជីវៈ ដល់ស្ត្រីពិការ<br>- អប់រំផ្សព្វផ្សាយតាមសហគមន៍ និងសាលារៀនអំពីច្បាប់យុត្តិធម៌អនីតិជន យេនឌ័រនិងគ្រឿងញៀន និងយេនឌ័រ និងជំងឺអេដស៍ ។ល។ | - ចំនួនមណ្ឌលស្ត្រីដែលបានសាងសង់បន្ថែម<br>- ចំនួនស្ត្រីរងគ្រោះដែលបានទទួលសេវាប្រឹក្សា និងផ្តល់ជំនាញវិជ្ជាជីវៈ<br>- ចំនួនវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីច្បាប់អនីតិជន គ្រឿងញៀន និង ជំងឺអេដស៍ដល់សហគមន៍ និងសាលារៀនដោយមានការទទួលខុសត្រូវយេនឌ័រ<br>- ចំនួនស្ត្រី និងបុរសក្នុងសហគមន៍ ដែលបានទទួលវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយ | - ចំនួនមណ្ឌលស្ត្រីពិការត្រូវបានកើនឡើង<br>- ការកើនឡើងនូវចំនួនស្ត្រីពិការដែលមានមុខរបរចិញ្ចឹមជីវិត<br>- ស្ត្រីនិងបុរសនៅតាមសហគមន៍ ព្រមទាំងសិស្សានុសិស្សតាមសាលារៀនមានការយល់ដឹងពីច្បាប់យុត្តិធម៌អនីតិជន គ្រឿងញៀន និងជំងឺអេដស៍ និងមានវិធានការទប់ទល់ |
| **យុទ្ធសាស្ត្រទី ៤: បង្កើនសេវាសុខុមាលភាពជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងស្តារលទ្ធភាពពលកម្ម** | | | |
| **គោលបំណង** | **សកម្មភាព** | **សូចនាករ** | **លទ្ធផលរំពឹងទុកឆ្នាំ ២០១៥** |
| ១- លើកកម្ពស់សុខុមាលភាពជនពិការ ជាពិសេសស្ត្រី និងកុមារីពិការ និងស្តារ លទ្ធភាពពលកម្មឱ្យកាន់តែប្រសើរឡើង | - ជ្រើសរើសស្ត្រី និងស្ត្រីពិការជាគ្រូបង្គោល ដើម្បីបង្កើនការផ្សព្វផ្សាយច្បាប់<br>- បញ្ជ្រាបយេនឌ័រទៅក្នុងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ | - ចំនួនស្ត្រីពិការជាគ្រូបង្គោល<br>- ចំនួនដងនៃការផ្សព្វផ្សាយច្បាប់<br>- លិខិតបទដ្ឋានគតិយុត្តមានការបញ្ជ្រាបយេនឌ័រ | - ជនពិការជាពិសេសស្ត្រីនិងកុមារីពិការ ទទួលបានការយកចិត្តទុកដាក់ក្នុងការបង្កើនសមត្ថភាពក៏ដូចជាតម្រូវការ |

| | | | |
|---|---|---|---|
| | - ស្វែងរកការគាំទ្រពីគ្រប់ស្ថាប័ន ដើម្បីបង្កើនការយកចិត្តទុកដាក់ដល់ជនពិការ ជាពិសេសសម្រាប់ស្ត្រី និងកុមារី | - ចំនួនស្ថាប័ន និងដៃគូដែលបានគាំទ្រ | |
| ២- បង្កើនសេវាសុខុមាលភាពដល់ស្ត្រី និងកុមារីពិការ | - ចងក្រងក្រុមជួយខ្លួនឯងដោយមានការចូលរួមពីស្ត្រីឱ្យបានទូទាំងប្រទេស<br>- ផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រីនិងកុមារីពិការ<br>- សម្របសម្រួលជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិដើម្បីទទួលបានសេវាមីក្រូហិរញ្ញវត្ថុ និងសេវាគាំទ្រផ្សេងៗទៀត | - ចំនួនក្រុមស្ត្រីចូលរួមក្នុងក្រុមជួយខ្លួនឯង<br>- ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដល់ស្ត្រី និងកុមារីពិការ<br>- សេវាមីក្រូហិរញ្ញវត្ថុនិងសេវាគាំទ្រផ្សេងៗ ត្រូវបានផ្តល់ឱ្យជនពិការ ជាពិសេសស្ត្រីនិងកុមារីពិការ | - ជនពិការជាពិសេសស្ត្រីនិងកុមារីពិការ មានជំនាញវិជ្ជាជីវៈ និងទទួលបានសេវាគាំទ្រផ្សេងៗ ទាក់ទងនឹងសង្គមកិច្ច ដើម្បីធ្វើឱ្យជីវភាពប្រសើរឡើង |
| ៣- រៀបចំចងក្រងទិន្នន័យស្ត្រី និងកុមារីពិការ | - សហការជាមួយក្រសួងកិច្ចការនារី និងក្រសួងមហាផ្ទៃក្នុងការប្រមូលទិន្នន័យស្ត្រី និងកុមារីពិការទូទាំងប្រទេស | - ទិន្នន័យស្ត្រី និងកុមារីពិការ | - ក្រសួងស.អ.យ មានទិន្នន័យស្ត្រី និងកុមារីពិការទូទាំងប្រទេស សម្រាប់ងាយស្រួលក្នុងការអភិវឌ្ឍ |

**យុទ្ធសាស្ត្រទី ៥: ពង្រឹងពង្រីករបបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ និងមន្ត្រីរាជការស៊ីវិលដោយមានការទទួលខុសត្រូវយេនឌ័រ**

| គោលបំណង | សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុកឆ្នាំ ២០១៥ |
|---|---|---|---|
| ១- ធានាបើកផ្តល់របបសន្តិសុខសង្គមឱ្យបានទាន់ពេលវេលា មានប្រសិទ្ធភាព តម្លាភាព និងដោយមានការទទួលខុសត្រូវយេនឌ័រ | - លើកគម្រោងផែនការថវិកាឱ្យបានម៉ត់ចត់ទាន់ពេលវេលា<br>- រៀបចំសំណុំបែបបទក្នុងការស្នើសុំប្រាក់របបសន្តិសុខសង្គមឱ្យបានឆាប់រហ័ស<br>- ជំរុញការបើកផ្តល់របបសន្តិសុខសង្គមតាមប្រព័ន្ធធនាគារ | - ទិន្នន័យមន្ត្រីរាជការស៊ីវិល និង អតីតមន្ត្រីរាជការស៊ីវិល<br>- មានគម្រោងផែនការថវិកាទាន់ពេលវេលា<br>- មានសំណុំបែបបទក្នុងការស្នើសុំប្រាក់របបសន្តិសុខសង្គម | ការបើកប្រាក់របបសន្តិសុខសង្គមបានទាន់ពេលវេលា |

| | | | |
|---|---|---|---|
| | - លុបបំបាត់ការទិញ និងលក់របប និងបំបាត់ភាពអសកម្មនានា | | |
| ២- លើកកម្ពស់សុខុមាលភាពមន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ជាពិសេសស្ត្រី | - រៀបចំលិខិតបទដ្ឋានគតិយុត្ត ក្នុងការកសាងរចនាសម្ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រង ការផ្តល់ធានារ៉ាប់រងសុខភាព ដោយការទទួលខុសត្រូវយេនឌ័រ<br>- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការ និងដៃគូអភិវឌ្ឍនានា | - លិខិតបទដ្ឋានគតិយុត្ត ក្នុងការកសាងរចនាសម្ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការគ្រប់គ្រង ការផ្តល់ធានារ៉ាប់រងសុខភាព ដោយការទទួលខុសត្រូវយេនឌ័រ<br>- ចំនួនក្រសួងស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍដែលបានសហការ | - កម្រិតអាយុមធ្យមរបស់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ជាពិសេសស្ត្រី កើនឡើង |
| ៣- រៀបចំយន្តការដើម្បីឱ្យមានបេឡាឥណទានសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល និងអនុគ្រោះការប្រាក់កាន់តែទាបបំផុត សម្រាប់ស្ត្រី | - បង្កើតបេឡាឥណទានសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ដោយបញ្ចូលការប្រាក់ទាបបំផុតសម្រាប់ស្ត្រី | - មានបេឡាឥណទាន សម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតមន្ត្រីរាជការស៊ីវិល ដែលបញ្ចូលការប្រាក់ទាប់បំផុតសម្រាប់ស្ត្រី | - កាត់បន្ថយការជួបផលវិបាក របស់មន្ត្រីរាជការ និងអតីតមន្ត្រីរាជការ ជាពិសេសស្ត្រី |
| ៤- កែសម្រួលរបបគោលនយោបាយសម្រាប់មន្ត្រីរាជការ និងអតីតមន្ត្រីរាជការស៊ីវិល ជាពិសេសសម្រាប់ស្ត្រី និងកុមារ | - លើកសំណើរការកែសម្រួលរបបគោលនយោបាយដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ សិក្សាវាយតម្លៃ និងសម្រេច | - របបគោលនយោបាយត្រូវបានកែសម្រួលដោយមានការទទួលខុសត្រូវយេនឌ័រ | - ស្ថានភាពសេដ្ឋកិច្ចរបស់មន្ត្រីរាជការ និងអតីតមន្ត្រីរាជការស៊ីវិលកើនឡើង |
| ៥- ពង្រឹងការគាំទ្រ និងការយកចិត្តទុកដាក់ដល់ជនចាស់ជរា ជាពិសេសស្ត្រីចូលរួមក្នុងផលប្រយោជន៍សង្គមដែលអាចឱ្យជនចាស់ជរាជួយខ្លួនឯងផងនិងសង្គមជាតិផង | - បង្កើនការផ្សព្វផ្សាយពីសារៈសំខាន់ នៃបញ្ហារបស់មនុស្សចាស់ ការការពារសិទ្ធិរបស់ជនចាស់ជរា ជាពិសេសស្ត្រីនៅតាមសហគមន៍ជាច់ស្រយាល<br>- ធ្វើការវិភាគយេនឌ័រ ក្នុងការស្រាវជ្រាវ ការធ្វើផែនការ ការវាយតម្លៃសកម្មភាពសម្រាប់ជនចាស់ជរា | - ចំនួនការផ្សព្វផ្សាយពីសារៈសំខាន់ នៃបញ្ហារបស់មនុស្សចាស់ និងការការពារសិទ្ធិរបស់ជនចាស់ជរា ជាពិសេសស្ត្រី នៅតាមសហគមន៍ដាច់ស្រយាល<br>- របាយការណ៍ការវិភាគយេនឌ័រ ក្នុងការស្រាវជ្រាវ ការធ្វើផែនការ ការវាយតម្លៃសកម្មភាពសម្រាប់ជនចាស់ជរា | - បុព្វហេតុផ្សេងៗ បានផ្តល់ឱកាសដល់ជនចាស់ជរាចូលរួម ដើម្បីរំដោះខ្លួនចេញពីការលំបាក<br>- ក្នុងយុទ្ធសាស្ត្រដ៏ទូលំទូលាយ ដើម្បីដោះស្រាយបញ្ហាភាពក្រីក្របានបញ្ចូលការរួមចំណែករបស់ជនចាស់ជរា ជាពិសេសស្ត្រី<br>- រាល់ផែនការរបស់ក្រសួង មានបញ្ចូលយេនឌ័រ |

| | | | |
|---|---|---|---|
| ៦- ផ្តល់ធានារ៉ាប់រងសង្គមជូនប្រជាពលរដ្ឋទូទៅទាំងស្ត្រី និងបុរស | - ជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការគ្រប់គ្រង លើការផ្តល់ធានារ៉ាប់រងសង្គម សម្រាប់ ប្រជាពលរដ្ឋទូទៅ ដែលជាកត្តាអនុគ្រោះដល់ជនងាយរងគ្រោះជាពិសេសស្ត្រី និងកុមារ | - មានលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការគ្រប់គ្រងលើការផ្តល់ធានារ៉ាប់រងសង្គម | - ប្រជាពលរដ្ឋទូទៅទាំងស្ត្រី បុរសត្រូវបានផ្តល់ធានារ៉ាប់រងសង្គម |
| **យុទ្ធសាស្ត្រទី ៦: ពង្រឹងពង្រីករបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន ដោយមានការទទួលខុសត្រូវយេនឌ័រ** | | | |
| គោលបំណង | សកម្មភាព | សូចនាករ | លទ្ធផលរំពឹងទុកឆ្នាំ ២០១៥ |
| ១- ពង្រឹងការអភិវឌ្ឍអតីតយុទ្ធជនដោយផ្តល់អាទិភាព ពិសេសដល់គ្រួសារយុទ្ធជនពលី មរណៈ និង ពិការ ជាពិសេសស្ត្រីមេគ្រួសារ | - បែងចែកដីលំនៅឋាន និង ដីសម្បទានសង្គមកិច្ច សម្រាប់បង្កបង្កើនផលដល់គ្រួសារយុទ្ធជនពលីមរណៈ និងពិការ ជាពិសេសស្ត្រីមេគ្រួសារ<br>- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធដើម្បីបង្កើនវិជ្ជាជីវៈ ជំនាញកសិកម្ម ដល់ស្ត្រីដែលជាសមាជិកគ្រួសារអតីតយុទ្ធជន<br>- សម្របសម្រួលក្នុងការទទួលបានសេវាមីក្រូហិរញ្ញវត្ថុ សម្រាប់ស្ត្រីនៅក្នុងគ្រួសារអតីតយុទ្ធជន | - ចំនួនគ្រួសារយុទ្ធជនពលី មរណៈ និងពិការ គ្រួសារដែលមានស្ត្រីជាមេគ្រួសារទទួលបានដីលំនៅឋាន និងដីសម្បទានសង្គមកិច្ច<br>- ជំនាញវិជ្ជាជីវៈ ជំនាញកសិកម្ម សេវាមីក្រូហិរញ្ញវត្ថុ ត្រូវបានផ្តល់ដល់ស្ត្រីដែលជាសមាជិកគ្រួសារអតីតយុទ្ធជន | - ជីវភាពអតីតយុទ្ធជន ជាពិសេសគ្រួសារយុទ្ធពលីមរណៈ ដែលមានស្ត្រីជាមេគ្រួសារត្រូវបានកើនឡើង |
| ២- លើកកម្ពស់វិស័យអតីតយុទ្ធជន ជាពិសេសគ្រួសារជនពលី មរណៈ ពិការ និវត្តជន និងជនបាត់បង់កម្លាំងពលកម្មជាពិសេសស្ត្រី | - រៀបចំរបបសន្តិសុខសង្គមដល់ស្ត្រីជាជនពិការនៅពេលសម្រាលកូន<br>- រៀបចំគោលការណ៍ដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុកម្តាយ អាណាព្យាបាលរបស់ជនពលី មរណៈ<br>- រៀបចំគោលការណ៍កែសម្រួលបន្ថែមប្រាក់ម្ហូបជូននិវត្តជន ជនបាត់បង់សមត្ថភាពនិងជនពិការទាំងបុរស និងស្ត្រី | - មានគោលការណ៍ផ្តល់របបសន្តិសុខសង្គមដល់ជនពិការជាស្ត្រីនៅពេលសម្រាលកូន<br>- មានគោលការណ៍តម្លើងប្រាក់ឧបត្ថម្ភប្រចាំខែជូនឪពុកម្តាយ និងអាណាព្យាបាល<br>- មានគោលការណ៍កែសម្រួលបន្ថែមប្រាក់ម្ហូបជូននិវត្តជន ជនបាត់បង់សមត្ថភាព និងជនពិការទាំងបុរស និងស្ត្រី | - ប្រាក់ឧបត្ថម្ភជូនគ្រួសារជនពលីមរណៈ ពិការ និវត្តជន និងជនបាត់បង់កម្លាំងពលកម្មជាពិសេសស្ត្រី ត្រូវបានតម្លើង |

# ឧបសម្ព័ន្ធ ៤: បញ្ជីត្រួតពិនិត្យសម្រាប់ការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធី ឬ គម្រោង

១- **សំណួរអំពីការវិភាគយេនឌ័រនៅពេលចាប់ផ្តើមរៀបចំគម្រោង**

តើការវិភាគយេនឌ័រត្រូវបានគេប្រតិបត្តិឬទេ ?

➢ បើសិនជាមាន:

- វិភាគដោយរបៀបណា? តើនរណាវិភាគ ?
- តើផលប្រយោជន៍អ្វីខ្លះដែលបុរស និងស្ត្រីទទួលបាន? តើបុរស និង ស្ត្រីចូលរួមអនុវត្តគម្រោងបានទទួលផលអ្វីខ្លះ?
- តើការវិភាគយេនឌ័រនេះមានគុណភាពល្អត្រឹមត្រូវឬទេ ?

➢ បើសិនជាគ្មានការវិភាគយេនឌ័រ:

- ហេតុអ្វីបានពុំមានការវិភាគយេនឌ័រ ? តើការវិភាគនេះនឹងធ្វើឡើងនៅពេលណា ?
- តើការវិភាគនេះនឹងផ្តោតលើអ្វីខ្លះ ?
- តើបច្ចុប្បន្ននេះមានព័ត៌មានអ្វីខ្លះ ?

២- **សំណួរអំពីការប្រើប្រាស់លទ្ធផលនៃការវិភាគយេនឌ័រ**

- តើលទ្ធផលនៃការវិភាគត្រូវបានបញ្ចូលទៅក្នុងការតាក់តែងគម្រោងដោយរបៀបណា ?
- តើលទ្ធផលនៃការវិភាគត្រូវបានបញ្ចូលទៅក្នុងការវិភាគបញ្ហាឬទេ?
- តើយុទ្ធសាស្ត្រដែលរៀបចំឡើងមានបញ្ចូលយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាយេនឌ័រ ?
- តើសកម្មភាពអ្វីខ្លះនឹងត្រូវបានរៀបចំឡើង ដើម្បីបញ្ហាយេនឌ័រដែលបានកំណត់ឡើងនៅតាមថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងរយៈពេលខ្លី និងរយៈពេលវែង? តើសកម្មភាពទាំងនោះនឹងត្រូវដាក់បញ្ចូលជាសកម្មភាពរបស់គម្រោងដែរឬទេ ?
- តើការប៉ាន់ប្រមាណនេះរួមបញ្ចូលសូចនាករដើម្បីតាមដាន និងប៉ាន់ប្រមាណពីលទ្ធផលលើស្ត្រី និងប្រជាជនក្រីក្រឬទេ ?
- តើលទ្ធផល នៃការវិភាគយេនឌ័រមានព័ត៌មានគ្រប់គ្រាន់ ដើម្បីប្រើប្រាស់ជាទិន្នន័យមូលដ្ឋាន និងទិន្នន័យបញ្ចប់គម្រោងដែរឬទេ ?

៣- **បុគ្គលិក និងការគ្រប់គ្រងគម្រោង**

- តើការជ្រើសរើសបុគ្គលិកឆ្លុះបញ្ចាំងពីតុល្យភាព និង សមធមិយេនឌ័រដែរឬទេ ?
- តើបុគ្គលិកជាស្ត្រីអាចចូលរួមក្នុងការសម្រេច និង ការគ្រប់គ្រងគម្រោងឬកម្មវិធីក្នុងកម្រិតណា ?
- តើគោលនយោបាយធនធានមនុស្សរបស់គម្រោងមានចែងអំពីច្បាប់មាតុភាព និងបិតុភាពដែរឬទេ ?
- តើបុគ្គលិករបស់គម្រោងត្រូវការការបណ្តុះបណ្តាលអំពីយេនឌ័រឬទេ?
- តើគម្រោងនឹងរៀបចំការបណ្តុះបណ្តាលសម្រាប់ការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងការរៀបចំផែនការ និងការអនុវត្តដែរឬ ?

៤- **ការវាយតម្លៃពាក់កណ្តាល និង ចុងបញ្ចប់នៃគម្រោង**

- តើការវាយតម្លៃនឹងផ្ដោតលើស្ទូចនាករយេនឌ័រនៅក្នុងគម្រោងដើម្បីធានាថាតម្រូវការផលប្រយោជន៍ និងអ្នកទទួលផលផ្សេងៗ ទទួលបានប្រយោជន៍ដូចគ្នា ?
- តើនឹងមានការវាយតម្លៃដាច់ដោយឡែក ដើម្បីដឹងវាស់ស្ទង់ពីលទ្ធផលទាក់ទងនឹងយេនឌ័រ និងប៉ាន់ប្រមាណពីផលប៉ះពាល់លើស្ត្រី និងក្រុមប្រជាជនក្រីក្រដូចដែលបានគ្រោងទុកឬអាចផ្ដល់ជាអនុសាសន៍បាន ?

**៥- ការគាំទ្រការបញ្ជ្រាបយេនឌ័រថ្នាក់ជាតិ**

- តើគម្រោង ឬកម្មវិធី នឹងគាំទ្រការបញ្ជ្រាបយេនឌ័រនៅក្នុងផែនការតាមវិស័យដូចជា ការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់ក្រសួងពាក់ព័ន្ធ?

**៦- សំណួរទាក់ទងថវិកា**

- តើថវិកាដែលលើកឡើងគ្រប់គ្រាន់សម្រាប់ការវិភាគយេនឌ័រ ការវាយតម្លៃការស្រាវជ្រាវឬទេ?
- តើថវិកាដែលស្នើឡើងគ្រប់គ្រាន់សម្រាប់ការប៉ាន់ប្រមាណផលប៉ះពាល់ផ្នែកយេនឌ័រដែរឬទេ?
- តើថវិកាដែលស្នើឡើងគ្រប់គ្រាន់សម្រាប់ការកសាងសមត្ថភាពក្នុងការបញ្ជ្រាបយេនឌ័រដែរឬទេ?

*កែសម្រួលពី UNDP Cambodia Gender Initiative 2007)*

## ឧបសម្ព័ន្ធ ៥: វាក្យសព្ទបច្ចេកទេសយេនឌ័រ

- **យេនឌ័រ:** គឺសំដៅយកតួនាទី ឥរិយាបថ និងតម្លៃទាំងឡាយដែលវប្បធម៌នានា និងសង្គមដាក់កំណត់ឱ្យបុរស និង ស្ត្រី អនុវត្តដោយឡែកពីគ្នាពីតួនាទី ឥរិយាបថ ហើយគុណតម្លៃទាំងនេះកំណត់នូវអាកប្បកិរិយា និង ទំនាក់ទំនងរវាងបុរស និងស្ត្រី ។ តួនាទី ឥរិយាបថ និង គុណតម្លៃទាំងនេះត្រូវបានបង្កើតឡើង និងថែរក្សាដោយស្ថាប័ន សង្គមនានា ដូចជា គ្រួសារ រដ្ឋាភិបាល សហគមន៍ សាលារៀន វត្តអារាម និងសារព័ត៌មាន។
- **ភេទ:** សំដៅលើភាពខុសគ្នាតាមធម្មជាតិ និង លក្ខណៈជីវសាស្ត្រដែលកំណត់មនុស្សណាមួយថាជាបុរស ឬជាស្ត្រី។ ភេទសំដៅយកលក្ខណៈរូបរាងកាយ និង សរីរាង្គរបស់មនុស្សម្នាក់ៗ។
- **ការយល់ដឹងពីយេនឌ័រ :** ការយល់ដឹងអំពីភាពខុសគ្នារវាងបុរស និងស្ត្រី ដែលសង្គមបានកំណត់ឡើងដោយឈរលើចំណេះដឹង ស្តីពីអាកប្បកិរិយានានាដែលជះឥទ្ធិពលទៅលើសមត្ថភាពនៃការទទួលបាន និងការគ្រប់គ្រងធនធាន ឱកាស និងផលប្រយោជន៍ ។
- **គម្លាតយេនឌ័រ:** ជាគម្លាតរវាងបុរស និង ស្ត្រីនៅក្នុងការចូលរួម ការទទួលបានសិទ្ធិ ឱកាស និងការគ្រប់គ្រងលើ ធនធាន និង ផលប្រយោជន៍នៅក្នុងវិស័យណាមួយ។
- **សមភាពយេនឌ័រ:** ជាភាពគ្មានការរើសអើង ដោយយកភេទរបស់បុគ្គលមកធ្វើជាមូលដ្ឋានក្នុងការបែងចែកធនធានឬការទទួលផលប្រយោជន៍ និងសេវាកម្មនានា ។ សមភាពយេនឌ័រអាចវាស់វែងបាន ដោយពិនិត្យលើកាលានុវត្តភាពស្មើគ្នា ឬការទទួលផលប្រយោជន៍ស្មើគ្នា។
- **សមធម៌យេនឌ័រ:** ជាដំណើរការនៃការប្រព្រឹត្តដោយយុត្តិធម៌ទៅលើស្ត្រី និងបុរសដើម្បីបន្ថយគម្លាតយេនឌ័រ និងឱ្យមានសមភាពយេនឌ័រ។
- **ការវិភាគយេនឌ័រ:** សំដៅលើដំណើរការវិភាគ និងពិនិត្យម៉ត់ចត់លើតួនាទីរបស់បុរស និងស្ត្រីដោយរួមបញ្ចូលបញ្ហាគន្លឹះនានាដូចជា ការបែងចែកកម្លាំងពលកម្ម សកម្មភាព ផលិតកម្ម និងការបន្តពូជ ការទទួលបាន និងការគ្រប់គ្រងធនធាន តម្រូវការ និងផលប្រយោជន៍ កត្តាសង្គម និងសេដ្ឋកិច្ចនានា ដែលមានឥទ្ធិពលលើបុរស និងស្ត្រី។ ការវិភាគយេនឌ័រត្រូវធ្វើឡើងនៅគ្រប់ជំហាននៃការរៀបចំផែនការ កម្មវិធី គម្រោងដោយចាប់ផ្តើមពីការកំណត់អាទិភាព ការប្រមូលទិន្នន័យ ការរៀបចំ ការអនុវត្ត ការតាមដាន និងវាយតម្លៃកម្មវិធី និងគម្រោង។
- **អព្យាក្រឹតភាពយេនឌ័រ:** ជាទស្សនៈមិនលំអៀងចំពោះទំនាក់ទំនងយេនឌ័រ ដែលជាទូទៅមិនអាចជួយដល់ដំណើរការនៃការខិតខំប្រឹងប្រែងឱ្យមានសមភាពយេនឌ័រ។
- **ភាពមិនមានទស្សនៈយេនឌ័រ:** ជាការមិនទទួលស្គាល់ និងមិនយកចិត្តទុកដាក់លើបញ្ហា តម្រូវការ និងការទទួលផលប្រយោជន៍ខុសគ្នារវាងបុរស និងស្ត្រីក្នុងការទទួលបានធនធាន ការធ្វើសេចក្តីសម្រេច និងតួនាទីខុសគ្នារវាងបុរសស្ត្រី និងកុមារាកុមារី ។ គោលនយោបាយមិនមានទស្សនៈយេនឌ័រសន្មតថាពុំមានខុសគ្នារវាងបុរស និងស្ត្រីទេ ។
- **ការបញ្ជ្រាបយេនឌ័រ:** ជាការដាក់បញ្ចូលបញ្ហា និងតម្រូវការរបស់បុរស និងស្ត្រីទៅក្នុងការវិភាគ ការប៉ាន់ប្រមាណ និងការតាមដានត្រួតពិនិត្យការរៀបចំ និងអនុវត្តកម្មវិធី គម្រោង គោលនយោបាយ និងច្បាប់នានា ដើម្បីធានាថាបុរស និងស្ត្រីបានចូលរួមក្នុងការអនុវត្ត ធ្វើសេចក្តីសម្រេច និង ទទួលផលប្រយោជន៍ស្មើគ្នា។

- **ការឆ្លើយតបតំរូវការយេនឌ័រ:** ជាការដោះស្រាយតម្រូវការបញ្ហា និងផលប្រយោជន៍ខុសគ្នារវាង បុរស ស្ត្រី និងកុមារា កុមារី ដើម្បីជៀសវាងការសន្មតថាបុរសស្ត្រី និងកុមារាកុមារីស្ថិតក្នុងស្ថានភាពដូចគ្នា ។
- **ថវិកាឆ្លើយតបយេនឌ័រ:** ជាការធានាថាបញ្ហាតម្រូវការ ផលប្រយោជន៍ និងការចូលរួមរបស់បុរសស្ត្រី និង កុមារកុមារី ត្រូវបានដោះស្រាយ និងដាក់បញ្ចូលនៅពេលរៀបចំ និងវិភាគថវិកាសម្រាប់ការអនុវត្តកម្មវិធី គម្រោង ឬ សកម្មភាពផ្សេងៗ។ ថវិកាយេនឌ័រដែលមានប្រសិទ្ធភាពត្រូវធានាថា បញ្ហាយេនឌ័រត្រូវបានវិភាគ និងដោះស្រាយចាប់តាំងពីការរៀបចំអនុវត្ត តាមដាន និងវាយតម្លៃគម្រោង និងកម្មវិធី ។
- **ទិន្នន័យបែងចែកតាមភេទ:** ជាស្ថិតិដែលពិពណ៌នាពីស្ថានភាពខុសគ្នារវាងបុរស ស្ត្រី និងកុមារាកុមារី ជាឧទាហរណ៍ចំនួនមន្ត្រីរាជការជាបុរស និងស្ត្រី ឬចំនួនកុមារា កុមារីកំពុងរៀននៅកម្រិតបឋមសិក្សា ។

## ឯកសារយោង


*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០* រាជរដ្ឋាភិបាលកម្ពុជា ខែធ្នូ ឆ្នាំ២០០៥ ។

*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២* រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៩ ។

*របាយការណ៍គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ២០០៣* ក្រសួងផែនការ ។

*របាយការណ៍ជឿនលឿនស្តីពីការអនុវត្តផែនការសកម្មភាពក្រុងប៉េកាំងអំពីបញ្ហាស្ត្រី ឆ្នាំ ១៩៩៥-២០០៥* ក្រសួងកិច្ចការនារី ខែធ្នូ ឆ្នាំ ២០០៤ ។

*អង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ ២០០០-២០០៥* វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងវិទ្យាស្ថានជាតិស្ថិតិ ភ្នំពេញ ខែធ្នូ ឆ្នាំ ២០០៦ ឧបត្ថម្ភដោយ UNFPA, UNICEF, USAID, ADB, DFID, និង CDC ។

*អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ ២០០៤* វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ភ្នំពេញ ខែកញ្ញា ឆ្នាំ ២០០៥ ។

*របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ ២០០៨ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ ២០០៩* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែមីនា ឆ្នាំ ២០០៩ ។

*របាយការណ៍បូកសរុបលទ្ធផលការងារ ៩ខែ ឆ្នាំ ២០០៩ និងទិសដៅអនុវត្តបន្ត* ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ-សម្បទា ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

*របាយការណ៍ស្តីពីការចុះអធិការកិច្ចការអនុវត្តបទដ្ឋានអប្បបរិមាសម្រាប់ការថែទាំជំនួស ចំពោះកុមារនៅក្នុងមណ្ឌលទូទាំងប្រទេសឆ្នាំ ២០០៩* ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

*កម្មវិធីការងាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសម្រាប់ឆ្នាំ ២០០៨-២០១៣* ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៩ ។

***Human Development Report 2006-2008***, UNDP.

***UNDP Cambodia Gender Initiative 2007***, UNDP Phnom Penh 2007.

***Cambodia Economic Watch,*** Economic Institute of Cambodia, 2007.

***Data from State Secretariat of Civil Service***, 2009.

***Violence Against Women: a baseline survey***, Ministry of Women's Affairs, Phnom Penh 2005.

***Gender Terminology,*** Ministry of Women's Affairs and JICA, Phnom Penh 2006.

***Do Social Safety Nets Catch Women?:*** *Women's Social Security Entitlements in the Arab World,* Iman Bibars, The Association for the Development and Enhancement of Women (ADEW), Cairo, Egypt.

***Social Safety Net for Women,*** Economic and Social Commission for Asia and the Pacific, The United Nations, New York, 2003.